ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

**និក្ខេបបទ**

# លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា

## ករណីសិក្សា ៖ ខេត្តតាកែវ

# Feasibility of Early Grade Reading Practice in Primary School

## Case Study: Takeo Province

ដោយ/by

**ឃិន សម្បត្តិ**

**KHEN SAMBATH**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៦**

**ឯកទេស ៖ ការគ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**ឧបត្ថម្ភដោយ ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation (CIESF)

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# លទ្ធភាពនៃការអនុវត្តការអំណានដំបូងនៅបឋមសិក្សា

## ករណីសិក្សា ៖ ខេត្តតាកែវ

## Feasibility of Early Grade Reading Practice in Primary School

## Case Study: Takeo Province


ដោយ / By

**ឃិន សម្បត្តិ**

**KHEN SAMBATH**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៦

ឯកទេស ៖ ការគ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩


សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត ឌី ខាំបូលី

សាស្ត្រាចារ្យដឹកនាំរង ៖ លោក ឌី បុណ្ណា



ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៧២៩ **អយក.** [illegible]

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីកា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមប្រកាសអះអាងថា និក្ខេបបទដែលមានចំណងជើងថា **លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា ករណីសិក្សា៖ ខេត្តតាកែវ** សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះ គឺជា ស្នាដៃសិក្សាស្រាវជ្រាវ របស់ខ្ញុំពិតប្រាកដមែន ។ ហើយស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញ លក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រ នៅវិទ្យាស្ថាន និងសាកលវិទ្យាល័យណាមួយឡើយ ។ បន្ថែមលើនេះទៅទៀតរាល់សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទនេះសុទ្ធតែបាន ចុះបញ្ជីក្នុងឯកសារយោងទាំងអស់ ។ និក្ខេបបទសិក្សាស្រាវជ្រាវខាងលើពិតជាត្រូវបានសិក្សា និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន ។

ថ្ងៃ .............................. ខែ ................. ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ................. ឆ្នាំ ២០១៩

ហត្ថលេខាបេក្ខជន

ឃិន សម្បត្តិ

# **លិខិតបញ្ជាក់**

ឯកឧត្តមបណ្ឌិត ឌី ខាំបូលី ជាសាស្ត្រាចារ្យដឹកនាំ
លោក ឌី បុណ្ណា ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា៖**

លោក **ឃិន សម្បត្តិ** និស្សិតថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា** (**ករណីសិក្សា៖ ខេត្តតាកែវ**)" ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៩

……………………………………………

ឯកឧត្តមបណ្ឌិត **ឌី ខាំបូលី**
**អគ្គនាយករង នៃអគ្គនាយកដ្ឋាន**
**គោលនយោបាយ និងផែនការ**

……………………………………………

លោក **ឌី បុណ្ណា**
**នាយករង នៃវិទ្យាស្ថានជាតិអប់រំ**

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទ ឃិន សម្បត្តិ ជានិស្សិតថ្នាក់បិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៧-២០១៩ ពិតជាមានសេចក្ដីសោមនស្សយ៉ាងរីករាយក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចះត្រចង់នេះ ខ្ញុំបាទក៏មិនភ្លេចផងដែរ ចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់ពីសំណាក់មជ្ឈដ្ឋានជាច្រើន ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ដំបូន្មាន ការឧបត្ថម្ភ និងផ្ដល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កាដូចសព្វថ្ងៃ។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណគណៈគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។ ជាពិសេសលោកបណ្ឌិត ឌី ខាំបូលី ដែលជាសាស្ត្រាចារ្យដឹកនាំ ដែលលោកតែងតែឆ្លៀតពេលវេលាដ៏មានតម្លៃរបស់លោក ក្នុងការផ្ដល់គំនិតណែនាំ ជាពុទ្ធិ ទ្រឹស្ដីល្អៗ និងផ្ដល់កម្លាំងចិត្ត បញ្ញា ស្មារតី បច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ លោកបានផ្ដល់ ជាឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញ ទិសដៅដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យជាស្ថាពរ ។

បន្ថែមពីនេះទៀតខ្ញុំក៏សូមថ្លែងអំណរគុណដល់ មិត្តរួមថ្នាក់ជំនាន់ទី៦ ទាំងអស់ដែលតែងតែផ្ដល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅ ។ លោកប្រធានការិយាល័យបឋមសិក្សានៃមន្ទីរអប់រំខេត្តតាកែវ លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ តាមសាលាគោលដៅទាំងអស់ ដែលបានចូល រួមសម្របសម្រួល ឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការចុះប្រមូលទិន្នន័យ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបាន ជោគជ័យ។

ជាទីបញ្ចប់នេះខ្ញុំបាទសូមគោរពជូនពរ និងប្រសិទ្ធពរ ជូនដល់ លោកអ្នកដ៏មានគុណទាំងពីរ ឯកឧត្ដម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជននិងកីឡា និងលោក លោកស្រី តំណាងអង្គការ CIESF មិត្តរួមថ្នាក់ និងក្រុមគ្រួសារ ព្រមទាំងភរិយា ព្រមទាំងកូនៗខ្ញុំបាទឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ក្រសួងអប់រំយុវជន និង កីឡាបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអនុវត្តគោលនយោបាយកំណែទម្រង់ ដោយផ្តែកលើសរសរស្តម្ភទាំងប្រាំក្នុងការលើកកម្ពស់វិស័យអប់រំឱ្យកាន់តែប្រសើរឡើង និង ដើម្បីធានាបាននូវគុណភាពអប់រំ ស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៥-២០៣០ ។ យ៉ាងណាមិញ យើងសង្កេតឃើញថា ការអប់រំនៅកម្រិតបឋមសិក្សា ពិសេសការសិក្សាថ្នាក់ដំបូងក្រសួង និងភាគីពាក់ព័ន្ធនានាបានចូលរួមបង្កើតកម្មវិធីអំណានដំបូងដើម្បីជួយលោកគ្រូ អ្នកគ្រូ លើវិធីសាស្រ្តបង្រៀនអំណាន និងការអានរបស់សិស្សានុសិស្សឲ្យទទួលបានគុណភាព ហើយកម្មវិធីនេះបានដាក់ឲ្យអនុវត្តសាកល្បងនៅខេត្តសៀមរាប និងខេត្តកំពង់ធំដោយទទួលបានប្រសិទ្ធភាពខ្ពស់គឺ៦៨% ដែលទិន្នន័យសិស្សចេះអាន( តេស្ត អឺហ្រ្គា ឆ្នាំ ២០១៧-២០១៨) ។ ដោយមើលឃើញលទ្ធផលយ៉ាងល្អដូច្នេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកប្រធានបទស្តីអំពី « លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា» មកធ្វើការស្រាវជ្រាវ ។

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមមន្ទីរអប់រំ ការិយាល័យអប់រំស្រុក ០៣ និងសាលារៀនចំនួន១០នៅបឋមសិក្សា នៅក្នុងខេត្តតាកែវ ។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើលទ្ធភាពនៃការអនុវត្តអំណានដំបូងនៅកម្រិតបឋមសិក្សារួមមាន ទ្រព្យធនដែលមានស្រាប់នៅតាមអង្គភាព មន្ទីរ ស្រុក សាលារៀន ធៀបទៅនឹងវិធីសាស្រ្តដែលមាននៅក្នុងសៀវភៅកញ្ចប់សម្ភារៈអំណានដំបូង។

ការសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យបឋមនៅតាមមន្ទីរ ស្រុក/ក្រុង និងសាលាគោលដៅ ដោយជ្រើសយកថ្នាក់ដឹកនាំមន្ទីរ ០១នាក់ ថ្នាក់ប្រធានការិយាល័យស្រុក ០៣នាក់ នាយកសាលា ១០នាក់ គ្រូបង្រៀន៥៥នាក់ ដើម្បីបំពេញនិងធ្វើការសម្ភាសន៍ ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី SPSS និង Excel ដែលវិភាគតាម Descriptive And Frequencies ដោយបង្ហាញជាតារាងស្ថិតិ និងដ្យាក្រាម ។

ការសិក្សាស្រាវជ្រាវ នេះបានរកឃើញថា លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា មានចំណុចល្អច្រើនដូចជា ១)មន្ទីរអប់រំខេត្តមានលទ្ធភាពអនុវត្ត ផ្អែកលើសមត្ថភាពរបស់គ្រូឧទ្ទេស ក្នុងការប្រជុំផ្លាស់ប្តូរបទពិសោធន៍ដល់គ្រូបង្គោលតាម

កម្រិតថ្នាក់ ២) ការិយាល័យក្រុង/ស្រុកមានលទ្ធភាពក្នុងការអនុវត្តដោយសារ គ្រូបង្រៀនធ្លាប់បានចូលរួមការបណ្តុះបណ្តាលថ្នាក់ទី១ រយៈពេល៨សប្តាហ៍ដំបូងក្នុងការអប់រំកុមារអាយុ៦ឆ្នាំមិនឆ្លងកាត់មតេយ្យសិក្សា និងតាមរយៈអង្គការដៃគូពាក់ព័ន្ធក្នុងការជួយឧបត្ថម្ភ ៣) នាយកសាលាក៏មានលទ្ធភាពក្នុងការអនុវត្តដែរ ពីព្រោះយើងមាន ការផ្លាស់ប្តូរបទពិសោធបង្រៀនតាមកម្រិតថ្នាក់ ដោយមានថវិកាគ្រោងទុក ផលិត និងចែកជូនសម្ភារៈ តាមដែលអាចធ្វើទៅបានតាមលទ្ធភាពរបស់សាលារៀន ៤) ចំណែកគ្រូបង្រៀនភាគច្រើនជាងពាក់កណ្តាលគឺមានលទ្ធភាពបង្រៀនអំណានដំបូងតាមរយៈការសម្ភាស និងវិភាគលើចម្លើយរបស់ពួកគាត់ធៀបទៅនឹងកញ្ចប់សម្ភារៈអំណានដំបូងដោយពួកគាត់ ធ្លាប់ដឹងធ្លាប់ចូលរួមកម្មវិធីបណ្តុះបណ្តាលវគ្គខ្លីៗ និងមានបទពិសោធបង្រៀនផ្ទាល់នៅកម្រិតថ្នាក់តូចៗច្រើនឆ្នាំ។ ប៉ុន្តែនៅមានបញ្ហាប្រឈមតិចតួចដែរគឺនាយកសាលាមួយចំនួនតូចមានប្រសាសន៍ថា ពួកគាត់ពុំមានលទ្ធភាពអនុវត្តកម្មវិធីនេះទេដោយផ្អែកលើហេតុផលដូចជា ៖ មិនទាន់យល់ច្បាស់ពីកម្មវិធីនេះ មិនមានសម្ភារៈឯកសារ មិនមានគ្រូឧទ្ទេស និងខ្វះថវិកាចំណាយលើកម្មវិធីអំណានដំបូង ។ រីឯគ្រូបង្រៀនមួយចំនួនទៀត គឺមានលទ្ធភាបបង្រៀនបានខ្លះដែរ ដោយសារពួកគាត់ធ្លាប់ដឹងនិងធ្លាប់មានបទពិសោធបង្រៀនកម្រិតថ្នាក់តូចពីមុនៗមក និងមួយចំនួនតូចទៀត គឺមិនអាចបង្រៀនបានទេ ពីព្រោះពួកគាត់ មិនធ្លាប់បានដឹង បានចូលរួមកម្មវិធីវគ្គខ្លីៗខាងអំណាន និងមិនមានបទពិសោធបង្រៀនពីមុនមកទេ ។

សរុបសេចក្តីមក លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា គឺអាចអនុវត្តទៅបានយ៉ាងពិតប្រាកដ ដោយផ្អែកតាមលទ្ធផល និងចម្លើយនៃការសិក្សាស្រាវជ្រាវដូចបានរៀបរាប់ជូនខាងលើ ។

# Abstract

The Ministry of Education has been paying close attention to the implementation of reform policies based on the five pillars to improve education and to ensure the quality of education in line with Sustainable Development Goals 2015-2030. However, we have found that primary education especially primary education, ministries and relevant institutions have been involved in setting up the early grade reading program to help teachers improve their students' reading and reading skills. Piloted in Siem Reap and Kampong Thom provinces with 68% efficiency Students read (testing EGRA, 2017-2018). In view of the positive results, the researchers selected the topic "The feasibility of implementing early grade reading in primary school" for research. The study was conducted at Education Department, 3 District of Education Office and 10 schools in primary schools in Takeo province.

This study focuses on the feasibility of implementing early literacy at the primary level, including existing assets in units such as district, school and competencies, department, city / district, principals and teachers, knowledge and experience compared to methods. Found in The Early Grade Reading Kit. The researchers used a questionnaire tool to conduct primary data collection at the district / municipality and target schools, providing one to the head of the department, three district heads, 10 principals, 55 teachers to complete and interview. The data collected by the researchers was analysed by SPSS and Excel by Frequency and Descriptive, presented as statistics and diagrams. This study found that the feasibility of implementing the initial reading program in primary school has several advantages: (1) Provincial Education Department is able to practice based on the ability of the trainers to exchange experience with trainers at all levels ,(2) District was able to apply because the teacher had attended the first 8 weeks of training 6-year-old early childhood education through kindergarten education and through partners involved in sponsorship, (3) The principal is also able to implement because we have the exchange of instructional experience at the budget level, planned to produce and distribute materials as much as possible to the school (4) Whereas more than half teachers were able to teach the early grade reading by interviewing and analysing their answers compared to the first batch of reading materials, they know that they have been involved in short training courses and have had years of teaching experience at a very small level. A few principals said he was unable to implement the program on the grounds that: the program was not well understood, had no materials, had no trainers, and budgeted of the early grade reading. Also, some teachers are able to teach because some of them have had previous teaching experience and some are not able to teach because they do not know the early grade reading program and no prior teaching experience.

In short, the feasibility of implementing early grade reading in primary school is truly feasible based on the research findings and answers described above.

Thanks!

# មាតិកា ទំព័រ


**លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ** .............................................i

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន**............................................................ii

**លិខិតបញ្ជាក់**.................................................................................iii

**លិខិតថ្លែងអំណរគុណ**.......................................................................iv

**មូលន័យសង្ខេប** ..............................................................................v

Abstract............................................................................................vii

**មាតិកា** .........................................................................................viii

**បញ្ជីតារាង** ...................................................................................xi

**បញ្ជីអក្សរកាត់**...............................................................................xii

**ជំពូកទី ១ ៖ សេចក្តីផ្តើម** ...................................................................... ១

១.១. សាវតា.............................................................................................. ១

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ.......................................................................៤

១.៣. គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ .............................................. ៧

១.៤. សំណួរស្រាវជ្រាវ........................................................................................ ៨

១.៥. ដែនកំណត់ និងវិសាលភាព ........................................................................ ៨

១.៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......................................................................៩

១.៧. គម្រោងស្រាវជ្រាវ ................................................................................ ១០

**ជំពូកទី២ ៖ រំឭកទ្រឹស្តី** ........................................................................១២

២.១.ប្រវត្តិនៃអំណាន ..................................................................................១២

២.១.១.និយមន័យនៃអំណាន ..........................................................................១២

២.១.១.១. ដូចម្តេចដែលហៅថា អំណាន?.............................................................១២

២.១.១.២.តើអំណានចាប់កំណើតតាំងពីពេលណា និងតាមធ្យោបាយអ្វីខ្លះ?............១២

២.១.១.៣. អំណានមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ........ ១៣
២.១.១.៤. ប្រភេទអ្នកអាន ........ ១៣
២.១.១.៥.ហេតុអ្វីចាំបាច់អានសៀវភៅ? ........ ១៤
២.១.១.៦. តើអំណានគួរចាប់ផ្តើមនិងបញ្ចប់នៅពេលណា?........ ១៦
២.១.១.៧.តើប្រទេសណាខ្លះដែលឲ្យតម្លៃការអានសៀវភៅច្រើនជាងគេ? ........ ១៦
២.១.១.៨. តើប្រជាជនខ្មែរចូលចិត្តអានសៀវភៅក្នុងកម្រិតណា? ........ ១៧
២.១.១.៩. តើលោកអ្នកគួរជ្រើសរើសសៀវភៅប្រភេទណាដើម្បីអាន? ........ ១៨
២.២.និយមន័យលទ្ធភាពអំណានដំបូង ........ ១៨
២.៣.ការបង្រៀនអំណានដំបូង ........ ១៩
២.៣.១.បំណិនទាំង៥នៃអំណាន ........ ១៩
២.៣.២.សកម្មភាពគោលទាំង ៧ នៃអំណានដំបូង ........ ២០
**ជំពូកទី ៣ ៖ វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ២៦
វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២៦
៣.១. ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ........ ២៦
៣.២. ទីកន្លែងសិក្សាស្រាវជ្រាវ ........ ២៦
៣.៣. ការជ្រើសរើសសំណាក ........ ២៦
៣.៤. ឧបករណ៍ស្រាវជ្រាវ ........ ២៧
៣.៥. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ ........ ២៨
៣.៥.១. កម្រងសំណួរសម្រាប់ថ្នាក់ដឹកនាំមន្ទីរ ........ ២៨
៣.៥.២. កម្រងសំណួរសម្រាប់ការិយាល័យស្រុក ........ ២៨
៣.៥.៣. កម្រងសំណួរសម្រាប់នាយក ........ ២៩
៣.៥.៤. កម្រងសំណួរសម្រាប់សម្ភាសលោកគ្រូអ្នកគ្រូ ........ ២៩

៣.៦. ដំណើរការប្រមូលទិន្នន័យ ..................................................................... ៣០

៣.៧. ការវិភាគទិន្នន័យ ..................................................................... ៣០

៣.៨. ក្រមសីលធម៌នៃការស្រាវជ្រាវ ..................................................................... ៣១

**ជំពូកទី ៤ ៖ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា** ..................................................................... ៣២

៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ ..................................................................... ៣២

៤.១.១. អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ ..................................................................... ៣២

៤.១.២. លទ្ធភាពនៃការអនុវត្តការអនុវត្តអំណានដំបូងនៅបឋមសិក្សា ..................................................................... ៣៧

៤.១.២.១. ការបង្រៀនស្គាល់ស្វរអក្សរថ្មី ..................................................................... ៣៧

៤.១.២.២. ការបង្រៀនស្គាល់តួអក្សរថ្មី ..................................................................... ៣៨

៤.១.២.៣. ការបង្រៀនអានព្យាង្គ និងពាក្យ ..................................................................... ៣៨

៤.១.២.៤.ការបង្រៀនពាក្យវាក្យសព្ទ ..................................................................... ៣៩

៤.១.២.៥. ការបង្រៀនអានល្បះ ..................................................................... ៣៩

៤.១.២.៦. ការបង្រៀនអានអត្ថបទខ្លី ..................................................................... ៤០

៤.១.២.៧. ការបង្រៀនសរសេរ ..................................................................... ៤១

**ជំពូកទី ៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ..................................................................... ៤២

៥.១. សេចក្តីសន្និដ្ឋាន ..................................................................... ៤២

៥.២. សំណូមពរ ..................................................................... ៤៣

**ឯកសារយោង** ..................................................................... ៤៥

**ឧបសម្ព័ន្ធ** .....................................................................

# បញ្ជីតារាង


| ឈ្មោះតារាង | ទំព័រ |
|---|---|
| តារាងទី ១៖ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ | ៣២ |
| តារាងទី២ ៖ កម្រិតវប្បធម៌ ថ្នាក់ដឹកនាំមន្ទីរ ស្រុក នាយក និងគ្រូបង្រៀន | ៣៣ |
| តារាងទី៣៖ បទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់មន្ទីរ | ៣៣ |
| តារាងទី៤៖ បទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់ស្រុក | ៣៣ |
| តារាងទី៥៖ បទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់នាយក | ៣៤ |
| តារាងទី៦៖ បទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ក្រុមគ្រូបង្រៀន | ៣៤ |
| តារាងទី៧៖ ចំនួនថ្នាក់គ្រប់គ្រងមន្ទីរបានដឹងពីកម្មវិធីអំណានដំបូង | ៣៥ |
| តារាងទី៨៖ ចំនួនថ្នាក់គ្រប់គ្រងស្រុកបានដឹងពីកម្មវិធីអំណានដំបូង | ៣៥ |
| តារាងទី៩៖ ចំនួននាយកដែលបានដឹងពីកម្មវិធីអំណានដំបូង | ៣៥ |
| តារាងទី១០៖ ចំនួនគ្រូបង្រៀនដែលបានដឹងពីកម្មវិធីអំណានដំបូង | ៣៥ |
| តារាងទី១១៖ ថ្នាក់មន្ទីរធ្លាប់ចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង | ៣៦ |
| តារាងទី១២៖ ថ្នាក់ស្រុកធ្លាប់ចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង | ៣៦ |
| តារាងទី១៣៖ នាយកធ្លាប់បានចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង | ៣៦ |
| តារាងទី១៤៖ គ្រូបង្រៀនធ្លាប់ចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង | ៣៦ |
| តារាងទី១៥៖ គ្រូដែលធ្លាប់បង្រៀនទាក់ទងពីសកម្មវិធីអំណានដំបូង | ៣៧ |
| តារាងទី១៦៖ គ្រូបង្រៀនទាក់ទងការបង្រៀនស្គាល់ស្វរ | ៣៧ |
| តារាងទី១៧៖ គ្រូបង្រៀនទាក់ទងការបង្រៀនស្គាល់តួអក្សរ | ៣៨ |
| តារាងទី១៨៖ គ្រូបង្រៀនទាក់ទងការបង្រៀនអានព្យាង្គ | ៣៨ |
| តារាងទី១៩៖ គ្រូបង្រៀនទាក់ទងការបង្រៀនវាក្យសព្ទ | ៣៩ |
| តារាងទី២០៖ គ្រូបង្រៀនទាក់ទងការបង្រៀនអានល្បះ | ៣៩ |
| តារាងទី២១៖ គ្រូបង្រៀនទាក់ទងការបង្រៀនអានអត្ថបទខ្លី | ៤០ |
| តារាងទី២២៖ គ្រូបង្រៀនទាក់ទងការបង្រៀនសរសេរ | ៤១ |

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| CIESF | Cambodia International Education Support Foundation |
| EGRA | Early Grade Reading Assessment |
| EGR | Early Grade Reading |
| WB | World Bank |
| USAID | United State Agency for International Development |
| AI | Arab Ideal |

# ជំពូកទី ១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១. សាវតា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខដឹកនាំប្រទេសជាងបីទសវត្សកន្លងមកនេះ យើងសង្កេតឃើញថា មានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរស្ទើរគ្រប់វិស័យទាំងអស់ដូចជា វិស័យហេដ្ឋារចនាសម្ព័ន្ធ មានផ្លូវថ្នល់ចាក់កៅស៊ូ បេតុងស្ពានអាកាសឆ្លងថ្នល់ ឆ្លងទន្លេ ខ្វាត់ខ្វែងជាច្រើនពាសពេញផ្ទៃប្រទេស ដែលអាចធ្វើដំណើរទៅទីជិតឆ្ងាយបានយ៉ាងងាយស្រួលនិងឆាប់រហ័ស ។ វិស័យសុខាភិបាល មានមន្ទីរពេទ្យរដ្ឋ និងឯកជននៅតាមគ្រប់រាជធានី ខេត្ត ក្រុង ស្រុក ឃុំ ដែលធ្វើឲ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការស្វែងរកកន្លែងពិនិត្យ និងព្យាបាលជំងឺបានដោយមិនចំណាយពេលវេលា និងថវិកាច្រើននោះទេ។ វិស័យទូរគមនាគមន៍ មានការប្រើប្រាស់ទូរស័ព្ទស្មាតហ្វូន ទូរសារ តេឡេក្រាម តាមរយៈប្រព័ន្ធ ហ្វាយហ្វៃ អ៊ិនធឺណិត និង អ៊ីមែលមានយ៉ាងរហ័សទាន់ចិត្ត។ វិស័យឧហប្បាហកម្ម និងកសិឧហប្បាកម្ម មានបណ្ដារោងចក្រផលិតសម្ភារៈប្រើប្រាស់ដូចជា រោងចក្រកាត់ដេរផលិតសម្លៀកបំពាក់គ្រប់ប្រភេទ រោងចក្រស្បែកជើង រោងចក្រផលិតគ្រឿងឧបភោគ និងបរិភោគ រោងចក្រកែច្នៃភោគផលកសិកម្ម និងឧហប្បាកម្មជាដើម។ វិស័យអចលនទ្រព្យ មានក្រុមហ៊ុនទិញដី និងសាងសង់ផ្ទះល្វែង វីឡាសម្រាប់លក់ក្នុងតម្លៃសមរម្យដែលអាចឲ្យប្រជាជនមានលទ្ធភាពទិញសម្រាប់ប្រកបរបរអាជីវកម្មរៀងៗខ្លួន។ វិស័យជាច្រើនទៀតដែលជាពិសេសក្នុងនោះ វិស័យអប់រំត្រូវបានរាជរដ្ឋាភិបាលដែលគ្រប់គ្រងដោយសម្ដេចអគ្គមហាសេនាបតិតេជោ ហ៊ុន សែន បានយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងន័យអភិវឌ្ឍធនធានសម័យតេជោ ជាធនធានប្រកបដោយមនសិការ សីលធម៌ គុណធម៌ សមត្ថភាពគុណភាព ប្រសិទ្ធភាព និងជាធនធានដែលមានសក្ដានុពលពេញលេញ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺដឹកនាំប្រទេសឲ្យក្លាយជាប្រទេសពីកសិកម្មទៅជាប្រទេសឧហប្បាកម្មនៅឆ្នាំ ២០២៥

ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេស អភិវឌ្ឍ នៅឆ្នាំ ២០៥០ នាពេលអនាគត។

ពិតប្រាកដណាស់ ប្រទេសជាតិមួយអាចរីកចម្រើនទៅបានអាស្រ័យលើការអភិវឌ្ឍធនធានមនុស្សប្រកបដោយមនសិការ ក្រមសីលធម៌ គុណធម៌ សក្តានុពល និងសមត្ថភាពពេញលេញគឺ ចំណេះដឹង និងជំនាញច្បាស់លាស់ ដើម្បីប្រកួតប្រជែងជាមួយធនធានមនុស្សនៃបណ្តាប្រទេសអភិវឌ្ឍក្នុងយុគសម័យសកលភាវូបនីយកម្មដ៏ទំនើបនេះ។ ដើម្បីឆ្លើយតបនឹងគោលនយោបាយរាជរដ្ឋាភិបាលក៏ដូចជាគោលនយោបាយអប់រំថ្នាក់ជាតិ ២០០៩-២០៣០ របស់ក្រសួងអប់រំយុវជន និងកីឡាបានអនុវត្ត ១.ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ២.លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ ៣.អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ ៤.ការអប់រំមានគុណភាព បរិយាបន្ន សមធម៌និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ។ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡាដែលស្ថិតនៅក្រោមការដឹកនាំរបស់ ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន បាន និងកំពុងដាក់ចេញនូវផែនការយុទ្ធសាស្ត្រកំណែទម្រង់ស៊ីជម្រៅជាច្រើនចំណុច ហើយបាននឹងកំពុងអនុវត្តយ៉ាងយកចិត្តទុកដាក់ខ្ជាប់ខ្ជួនផងដែរ ។ លើសពីនេះក្រសួងបានអនុវត្តកំណែទម្រង់ការប្រឡងទាំងពីរកម្រិតគឺ កម្រិតមធ្យមបឋមភូមិ និងកម្រិតមធ្យមសិក្សាទុតិយភូមិស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងក៏ដូចជាថ្នាក់ជាតិ ក្នុងគោលបំណងពង្រឹងសមត្ថភាពលទ្ធផលសិក្សាសិស្ស ក៏ដូចជាគុណភាព និងប្រសិទ្ធអប់រំ។ ក្នុងឆ្នាំសិក្សាកន្លងមក ក្រសួងបានកែទម្រង់លើការប្រលងថ្នាក់មធ្យមសិក្សាបឋមភូមិ និងថ្នាក់មធ្យមសិក្សាទុតិយភូមិទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ ប៉ុន្តែយើងសង្កេតឃើញថាការប្រឡងឆ្លងពីបឋមសិក្សាឆ្លងទៅ អនុវិទ្យាល័យនៅតែមិនទាន់មានគុណភាពនៅឡើយ គឺមានតែបរិមាណ ។ ចំណែកឯក្រុមគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ បានលើកឡើងថា សិស្សដែលប្រឡងឡើងពីទី៦ទៅទី៧ គឺមិនមានសមត្ថភាពអានអក្សរបានត្រឹមត្រូវច្រើននាក់ និងខ្លះទៀតថា ភាគច្រើនមិនចេះអានតែម្តង (អត្ថបទស្សនៈព្រឹត្តិការណ៍ខ្មែរ សំឡេងពិភពលោក) ។ ការប្រលងកម្រិតបឋម

សិក្សាឆ្លងទៅមធ្យមសិក្សាបឋមភូមិ ផ្តោតសំខាន់លើការពង្រឹងសមត្ថភាពអំណាន សរសេរ ការគណនាលេខរបស់សិស្ស ។ អំណានជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការរៀនមុខវិជ្ជាដទៃ ដើម្បីពង្រឹងគុណភាពអំណានយើងសង្កេតឃើញនៅតាមសាលានីមួយៗគ្រប់កម្រិតមានបណ្ណាល័យដែលមានសៀវភៅជាច្រើន និងមានបណ្ណារក្សសម្រាប់ជួយពួកគេក្នុងការអានឲ្យបានស្ទាត់ជំនាញ។ បន្ថែមលើនេះទៅទៀត យោងតាមអនុក្រឹត្យដែលបានចុះហត្ថលេខាដោយសម្តេចអគ្គមហាសេនាបតិតេជោ ហ៊ុន សែន នៅថ្ងៃទី១៤ ខែកញ្ញា គឺរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី១១ ខែមីនា ជារៀងរាល់ឆ្នាំជាទិវាជាតិអំណាននៃព្រះរាជាណាកម្ពុជា ដើម្បីបណ្តុះទម្លាប់អាន ជំរុញនូវវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតាក់តែងនិពន្ធ រួមចំណែកការពារ និងពង្រឹងវប្បធម៌ខ្មែរ ។ អនុក្រឹត្យបន្តថាគ្រប់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការអន្តរជាតិ វិស័យឯកជន និងគ្រឹះស្ថានសិក្សានានា ត្រូវចូលរួមបំផុសមន្ត្រីរាជការ សិស្ស និស្សិត និយោជិត និយោជក កងកម្លាំងប្រដាប់អាវុធ និងប្រជាជនដើម្បីបង្កើតស្មារតីប្រឡងប្រណាំងអាន និងតែងនិពន្ធ។ ក្នុងនោះដែរលោកស្រី ខ្លួត វិបុលឡា នាយិកាបណ្ណាល័យជាតិបាននិយាយថា មានសិស្ស និស្សិតប្រមាន១០០ ទៅ១៥០នាក់បានចូលមកអានសៀវភៅសិក្សាស្រាវជ្រាវ ព្រោះនៅបណ្ណាល័យជាតិមានផ្ទុកសៀវភៅឯកសារ អនុក្រឹត្យនានាទាំងអស់ តែសម្រាប់ទម្លាប់អានរបស់ប្រជាជនកម្ពុជា គឺនៅមានកម្រិតតិចតួចនៅឡើយ ។ ចំណែកលោក ហុកសិទ្ធ នាយកអង្គារស៊ីប៉ា និងជាប្រធានសមាគមន៍បណ្ណារក្ស និងឯកសារវិទូកម្ពុជា បានថ្លែងថាការបង្កើតទិវាអំណានជាតិរបស់រាជរដ្ឋាភិបាល គឺបង្កើតឲ្យមានព្រឹត្តិការណ៍ជាថ្នាក់ជាតិបណ្តុះគំនិតដល់ពលរដ្ឋក្នុងការទម្លាប់អាន ។ លោកថាការអានរបស់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិតដោយសារយើងធ្លាប់ឆ្លងកាត់សង្គ្រាម ការចំណាកស្រុក ខ្វះសៀវភៅអាន និងខ្វះអ្នកនិពន្ធជាដើម។ លោកបានបន្តថា យើងសង្ឃឹមថានឹងមានផលវិជ្ជាមានដែលជាកម្លាំងរួមគ្នាពញ្ញាក់អារម្មណ៍ ឲ្យមានការទម្លាប់អាន ព្រោះយើងដឹងហើយថា អានច្រើន ចេះច្រើន។ ដោយឡែក ក្នុងឆ្នាំ ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តថវិកាជាតិចំនួន ១៨.៣១%សម្រាប់វិស័យអប់រំ (របាយការណ៍ដែលបានចុះផ្សាយរបស់កាសែតភ្នំពេញ

ប៉ុស្តិ៍)។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងអនុវត្តនូវកំណែទម្រង់វិស័យអប់រំដោយផ្តោតលើសសរស្តម្ភចំនួន ៥ គឺ ទី១៖ ការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយគ្រូបង្រៀន ទី២៖ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សា ព្រមទាំងការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានសាលារៀន ទី៣៖ ការធ្វើអធិការកិច្ច ទី៤៖ ការពង្រឹងការវាយតម្លៃការសិក្សា និងទី៥៖ ការធ្វើកំណែទម្រង់ការសិក្សាថ្នាក់ឧត្តមសិក្សា។ ជាងនេះទៅទៀត ស្របតាមសសរស្តម្ភទី២គឺការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សា ព្រមទាំងការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានសាលារៀន ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាលើសៀវភៅសិក្សាគោលថ្មីពីថ្នាក់ទី១ដល់ទី៣

ក្នុងឆ្នាំ២០១០ និងដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ ២០១១-២០១២-២០១៣ ទូទាំងប្រទេស ក្នុងគោលបំណងជួយដល់គ្រូងាយស្រួលក្នុងការបង្រៀនអំណាន និងដើម្បីបញ្ឈប់កង្វល់ពីមុនដែលការអានរបស់សិស្សទទួលបានលទ្ធផលទាប ហើយមិនទទួលបានលទ្ធផលជោគជ័យ (ស្តង់ដាអំណាន)។ បន្ថែមលើនេះទៀតសោត ក្នុងក្រសួងអប់រំ រួមទាំងដៃគូអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា បានដាក់បញ្ចូលកម្មវិធីថ្មីមួយទៀត ដើម្បីជួយបន្ថែមលើការបង្រៀនអំណានដល់សិស្ស ដោយសង្កត់ធ្ងន់ទៅលើការស្គាល់សូរ ការស្គាល់តួអក្សរ ការចេះអានព្យាង្គ និងពាក្យ ការចេះវាក្យសព្ទ ការចេះអានល្បឿន ការចេះអានអត្ថបទខ្លី និងការសរសេរ ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឲ្យសិស្សានុសិស្សមានទម្លាប់ក្នុងការអានពេញមួយជីវិត ក្រសួងអប់រំយុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍនានាបានបង្កើតកម្មវិធីអំណានដំបូងក្នុងគោលបំណងពង្រឹងការអាន និងបណ្តុះគំនិតអានការរបស់សិស្សឲ្យមានឥរិយាបថចូលចិត្តអានសៀវភៅ នៅតាមសាលារៀនទូទាំងប្រទេស ពិសេសសាលាកម្រិតបឋមសិក្សា។ ដើមឆ្នាំ ២០១៧ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិបានចាប់ផ្តើមនូវកម្មវិធីថ្មីមួយហៅថា កម្មវិធីអំណានថ្នាក់ដំបូង (Early Grade Reading) ដើម្បីជួយដល់ក្រសួងអប់រំ យុវជននិងកីឡាក្នុងការអភិវឌ្ឍនូវកម្មវិធីអំណានដំបូងថ្នាក់ជាតិមួយប្រកបដោយស៊ីសង្វាក់ និងស្ថិតស្ថេរ។ កម្មវិធីដែលមានរយៈពេលប្រាំឆ្នាំនេះ គឺ

២០១៧ ដល់ ២០២១ នឹងជួយធ្វើអោយប្រសើរឡើងនូវជំនាញក្នុងការអានរបស់កុមារ ដែលសិក្សានៅថ្នាក់ទី ១ ដល់ថ្នាក់ទី៣ ដោយផ្អែកលើវិធីសាស្ត្រមួយទៀងទាត់ ដែលអាចធ្វើបាន និងមានភាពប្រាកដប្រជាក្នុងប្រទេសកម្ពុជា និងដែលអាចយកទៅអនុវត្តបាននៅទូទាំងប្រទេ(USAIDទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ)។

ទោះបីជាថ្មីៗនេះ មានការលើកកម្ពស់ប្រសិទ្ធភាពអំណានសម្រាប់កុមារកម្ពុជា ហើយតាំងពីមានការកែទម្រង់កម្មវិធីសិក្សាទូទៅថ្នាក់ជាតិមកពីឆ្នាំ២០១០ដល់ ២០១៣ក៏ដោយ កាលឆ្នាំ ២០១៤ ថា ជាទូទៅពិន្ទុអំណាននៅតែទាបមិនអាចទទួលយកបាន ព្រមទាំងឃើញថា កុមារជាង ២៥% នៅតែមានសមត្ថភាពអានទាបជាងស្តង់ដា ។ សមត្ថភាពអាន គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀនមុខវិជ្ជាដទៃទៀត ហើយការធ្លាក់ចុះនៃប្រព័ន្ធអប់រំ ក្នុងការសម្រេចបានប្រសិទ្ធភាពខ្ពស់នៃអំណាននៅថ្នាក់ដំបូង ធ្វើឱ្យលទ្ធផលសិក្សាធ្លាក់ចុះនៅឆ្នាំបន្តបន្ទាប់ (របាយការណ៍របស់ World Bank កាលឆ្នាំ ២០១៤ ) ។

ក្រសួងអប់រំ យុវជននិងកីឡា បានជ្រើសយកខេត្តកំពង់ធំ ជាគោលដៅក្នុងការបើកវគ្គបំប៉ន ស្តីពីការអនុវត្តសាកល្បងកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង ដល់លោកគ្រូអ្នកគ្រូថ្នាក់ទី ១។ ក្នុងពិធីបើកសិក្ខាសាលាបំប៉ន ស្តីពីការ អនុវត្តន៍សាកល្បងកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងនៅខេត្តកំពង់ធំ កាលពីព្រឹកថ្ងៃទី១៦ខែតុលាឆ្នាំ២០១៨នេះ ឯកឧត្តម បណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្រសួងអប់យុវជននិងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ ១.កំណែទម្រង់គ្រប់គ្រងការសិក្សាផ្តោតលើការវាយតម្លៃរបស់សិស្ស ២. កំណែទម្រង់គ្រប់គ្រងរដ្ឋបាល ផ្តោតលើការធានា ការចូលរួមរបស់មាតាបិតាសិស្សនិងសហគមន៍ ការអនុវត្តគ្រប់គ្រងតាមសាលារៀន និងការអនុវត្តផែនកាយុទ្ធសាស្ត្រវិស័យអប់រំកំណែទម្រង់គ្រប់គ្រង់ហិរញ្ញវត្ថុផ្តោតការបង្កើនស្វ័យភាព និងគណនេយ្យភាព ហិរញ្ញវត្ថុសាលារៀនការធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ បង្កើនការបែងចែកថវិកា ផ្សារភ្ជាប់និងគោលការអប់រំ ៤.កំណែ

ទម្រង់ការគ្រប់គ្រង់ធនធានមនុស្សផ្តោតលើការបណ្តុះបណ្តាលដោយវិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែងបង្កើនបណ្តុះបណ្តាលគ្រូបង្រៀន និងអនុវត្តវាយតម្លៃការងារការបន្តអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈជាប្រចាំ គឺទាមទារឲ្យមានកម្មវិធីបំប៉នច្បាស់លាស់ មានសម្ភារៈនិងឯកសារបំប៉ន ប្រកបដោយគុណភាពនិងត្រូវមានគ្រូឧទ្ទេសប្រកបដោយសមត្ថភាព និងបំណិនខ្ពស់។

តាមរយៈកម្មវិធីនេះ គ្រូបង្រៀនទាំងអស់នឹងទទួលបានការបំប៉នយ៉ាងទៀងទាត់ ឆ្លើយតបទៅនឹងចំណុចខ្វះខាតដែរពួកគាត់មាន និងការសិក្សា ដើម្បីឆ្លើយតប ទៅនឹងសំណូមពរខាងលើនេះ ក្រសួងបាននិងកំពុងដឹកនាំក្រោមការសម្របសម្រួលរបស់អង្គការ (RTI) ព្រមទាំងមានការចូលរួមពីដៃគូរពាក់ព័ន្ធ ផលិតបាននូវសម្ភារៈ និងឯកសារបំប៉នផ្អែកតាមបទពិសោធន៍ និងលទ្ធផលនៃការអភិវឌ្ឍកន្លងមកដោយមានឈ្មោះថា កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង សៀវភៅណែនាំគ្រូ សៀវភៅជំនួយសិស្ស ប័ណ្ណអក្សរ រូបភាព និងសៀវភៅរឿងខ្លីៗ សម្ភារៈទាំងនេះគឺត្រូវបំប៉នលោកគ្រូអ្នកគ្រូបង្រៀនថ្នាក់ទី ១ រយៈពេល៩ថ្ងៃដើម្បីឲ្យលោកគ្រូអ្នកគ្រូទទួលបានពីរការបំប៉ន អាចយកទៅអនុវត្តបានត្រឹមត្រូវ ទៀងទាត់ចុងក្រោយគឺសិស្សថ្នាក់ទី១ ទទួលបានអំណានទាំងអស់គ្នា។

លោក ចន ខូលីន តំណាងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិកប្រចាំកម្ពុជាថ្លែងថាគម្រោងអនុវត្តនេះ គឺជួយពង្រឹងថ្នាក់ដំបូងនៅកម្ពុជា គម្រោងនេះត្រូវបានអនុវត្តនៅក្នុង ៤០ ប្រទេស ហើយមានកុមារប្រហែល៧០លាននាក់ កំពុងបានទទួលផលនៃការអនុវត្តគម្រោង និងការកសាងឯកសារកញ្ចប់សម្ភារៈអំណានដំបូងសម្រាប់វគ្គបំប៉នេះ មានការដឹកនាំដោយក្រសួងអប់រំនិងមានការចូលរួមចែករំលែកពីអង្គការដៃគូរ ពាក់ព័ន្ធ អ្នកឯកទេសអប់រំ និងគ្រូ ។

ឯកឧត្តម ហួនវ៉ាន់និត អភិបាលរង ខេត្តកំពង់ធំ មានប្រសាសន៍ថា ក្នុងនាម ជាអាជ្ញាធរខេត្តបានថ្លែងអំណរគុណ ដល់ក្រសួងអប់រំនិងមន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ទាំងអស់ ព្រមទាំងដៃគូរអភិវឌ្ឍន៍បានជ្រើសរើសយកខេត្តកំពង់ធំ ជាខេត្តគោលដៅ បើកវគ្គបំប៉នសាកល្បងគម្រោង និងខិតខំជម្រុញឲ្យវិស័យអប់រំទទួលបាននូវការរីកចម្រើនគួរ

ជាទីមោទនភាពក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន ព្រោះថាវគ្គបំប៉ន នេះមានសារៈដល់មន្ត្រីគ្រប់គ្រង និងគ្រូបង្រៀនគ្រប់លំដាប់ថ្នាក់ ព្រោះវគ្គបំប៉ននេះនឹងផ្តល់ចំណេះដឹង និងបច្ចេកទេសបង្រៀន អំពីការអាន សសេរ របស់សិស្សថ្នាក់ទី១ ដល់លោកគ្រូអ្នកគ្រូទូទាំងខេត្ត ព្រមទាំងយល់ដឹងពីវិធីសាស្ត្របង្រៀន ឲ្យមានភាពច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព និងគុណភាពកាន់តែប្រសើរឡើង(ព័ត៌មានស្លឹករិទ្ធ និង ផែនការយុទ្ធសាស្ត្រ២០១៩-២០២៣)។

ដោយឡែកក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើក្រសួងអប់រំ និងដៃគូអភិវឌ្ឍនានាបានបង្កើតកញ្ចប់សម្ភារៈអំណានដំបូងឡើងដើម្បីពង្រឹងគុណភាពអប់រំនៅកម្ពុជា។ ផ្អែកតាមរបាយការណ៍ទៅលើការធ្វើតេស្តអឺហ្គ្រា (EGRA) បានបង្ហាញថាចំនួនសិស្សចេះអានបានស្មើនឹង៦៨% លទ្ធផលនេះសបញ្ជាក់ឲ្យឃើញថាការអានរបស់សិស្សមានការរីកចម្រើន និងជោគជ័យគួរឲ្យកោតសរសើរ។

## ១.៣. គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ

ដោយស្របតាមលទ្ធផលរបស់តេស្តអឺហ្គ្រា ដែលបានបង្ហាញថាសិស្សមានការអានរីកចម្រើន អ្នកស្រាវជ្រាវមានគោលបំណងចង់រកឲ្យឃើញពី «លទ្ធភាពនៃការអនុវត្តកម្មវិធីអំណានដំបូងនៅបឋមសិក្សា»។ ក្នុងនាមខ្ញុំជាបុគ្គលិកអប់រំម្នាក់ ក៏ដូចជាអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រអប់រំផងដែរនោះ ខ្ញុំនឹងចាប់ផ្តើមធ្វើការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់អស់ពីសមត្ថភាពទៅលើប្រធានបទ "លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា" ដើម្បីសិក្សាស្វែងយល់អំពីអ្វីៗដែលទាក់ទងលោកគ្រូអ្នកគ្រូ រួមមានសមត្ថភាព ចំណេះដឹង ចំណេះធ្វើបទពិសោធ និងធនធាននានាដែលមានស្រាប់សម្រាប់ការអនុវត្តអំណានដំបូងសាលាបឋមសិក្សា។ ការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ជាព័ត៌មានសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំ និងដៃគូអភិវឌ្ឍការអប់រំ អ្នកសិក្សាជំនាន់ក្រោយៗ ដើម្បីយកទៅសិក្សាបន្ត និងអ្នកដែលពាក់ព័ន្ធទាំងអស់នានា ជាពិសេសគឺថ្នាក់ដឹកនាំក្រសួងអប់រំធ្វើការវិភាគ និងដាក់ឲ្យថ្នាក់ក្រោមជាតិអនុវត្តកម្មវិធីអំណានដំបូងនេះឆាប់ៗនៅទូទាំងប្រទេស។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងដើម្បីឲ្យការសិក្សាស្រាវជ្រាវមានលក្ខណៈស៊ីជម្រៅបែបវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវបានដាក់ចេញនូវសំណួរស្រាវជ្រាវខាងក្រោម៖

- តើការអនុវត្តអំណានដំបូងនៅសាលាបឋមសិក្សា អាចមានលទ្ធភាពប្រព្រឹត្តទៅបានដែរឬទេ?

## ១.៥. ដែនកំណត់ និងវិសាលភាព

ដើម្បីឲ្យការស្រាវជ្រាវមានលក្ខណៈបែបវិទ្យាសាស្ត្រពិតប្រាកដ ប្រកបដោយប្រសិទ្ធភាព និងដើម្បីឲ្យការសិក្សាស្រាវជ្រាវកាន់ស៊ីជម្រៅ អ្នកស្រាវជ្រាវនឹងលើកយកកត្តាមួយចំនួនដែលមាននៅសាលាបឋមសិក្សាមកសិក្សាស្រាវជ្រាវដូចជា៖

កត្តាមនុស្សគឺ សំដៅដល់សមត្ថភាពលោកគ្រូអ្នកគ្រូ សមត្ថភាពនាយកសមត្ថភាពថ្នាក់ដឹកនាំអប់រំស្រុក និងសមត្ថភាពថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត ។

កត្តាធនធានដែលមានស្រាប់ក្នុងអង្គភាព គឺ សំដៅដល់សាលារៀន គ្រូ សិស្សកម្មវិធីសិក្សា សៀវភៅសិស្ស សៀវភៅណែនាំគ្រូពីវិធីសាស្ត្របង្រៀន សម្ភារៈឧបទេសនិងកញ្ចប់ថវិកាដំណើរការសាលារៀន ។

អាស្រ័យដោយថវិកា និងពេលវេលាមានកំណត់ អ្នកស្រាវជ្រាវកំណត់យកករណីសិក្សានៅខេត្តតាកែវ ចំនួន៣ស្រុក មានក្រុងដូនកែវ ស្រុកគិរីវង់ និងស្រុកកោះអណ្តែត (ទីក្រុង ទីប្រជុំជន និងទីជនបទ) ដែលមានសាលាសរុបចំនួន១០សាលារៀន ការិយាល័យស្រុកចំនួន ៣ និងមន្ទីរអប់រំខេត្ត នីមួយៗមកធ្វើជាភាគសំណាក។ ចំពោះក្រុមគោលដៅដែលនិងត្រូវធ្វើការសម្ភាស និងបំពេញកម្រងសំណួររួមមានដូចជា៖

- លោកគ្រូអ្នកគ្រូចំនួន ៥៥ នាក់
- នាយកសាលាចំនួន ១០ នាក់
- ប្រធានការិយាល័យអប់រំស្រុកចំនួន ០៣ នាក់
- ប្រធានមន្ទីរអប់រំខេត្តតាកែវ ០១ នាក់
- សរុបរួម ៦៩ នាក់

## ១.៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

លទ្ធផលស្រាវជ្រាវត្រូវបានរៀបចំជានិក្ខេបបទ សម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំមាន ៥ជំពូកដូចខាងក្រោមៈ

**ជំពូកទី១ សេចក្តីផ្តើម**

ជំពូកនេះបង្ហាញអំពី សារតានៃការស្រាវជ្រាវ ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធ និងគម្រោងស្រាវជ្រាវ នៃនិក្ខេបបទទាំងមូល។

**ជំពូកទី២ រំលឹកទ្រឹស្តី**

ជំពូកនេះរៀបរាប់អំពីទ្រឹស្តីនិង វិធីសាស្រ្តបង្រៀនអំណានទាំងឡាយណាដែលទាក់ទៅនឹងប្រធានបទទាំងមូល ដែលមានដូចជា ៖ ប្រវត្តិនៃអំណាន និយមន័យនៃអំណាននិយមន័យអំណានដំបូង ហេតុដែលនាំឲ្យការបង្រៀនអំណានដំបូង ការបង្រៀនអំណានដំបូង វិធីសាស្រ្តបង្រៀនអំណានដំបូង បំណិនទាំង៥នៃអំណាន សកម្មភាពគោលទាំង៧នៃអំណានដំបូង ។

**ជំពូកទី៣ វិធីសាស្រ្តស្រាវជ្រាវ**

បង្ហាញអំពីគម្រោងដំណើរការស្រាវជ្រាវមានដូចជាៈ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ទីកន្លែងសិក្សាស្រាវជ្រាវ ការជ្រើសរើសភាគសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ កម្រងសំណួរសម្រាប់ថ្នាក់ដឹកនាំមន្ទីរ កម្រងសំណួរសម្រាប់ការិយាល័យស្រុក កម្រងសំណួរសម្រាប់នាយកសាលា កម្រងសំណួរសម្រាប់គ្រូ កម្រងសំណួរសម្រាប់សម្ភាសលោកគ្រូអ្នកគ្រូ ដំណើរការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ។

**ជំពូកទី៤ លទ្ធផល និងការវិភាគ**

រៀបរាប់ពីលក្ខណៈជាក់ស្តែងដែលបានធ្វើការស្រាវជ្រាវ និងវិភាគទៅលើព័ត៌មានទាំងអស់ដែលបានចុះប្រមូលតាមសាលារៀនជាក់ស្តែងថា តើវាដូចទៅនឹងទ្រឹស្តីដែរឬទេ? គឺក្នុងគោលបំណងរកឲ្យឃើញភាពដែលអាចធ្វើទៅបានដោយមាន

ចំណេះដឹង ចំណេះធ្វើ បទពិសោធ និងធនធានដែលមានស្រាប់ក្នុងការអនុវត្តអំណាន ដំបូងនៅបឋមសិក្សា ដែលយកចេញពីការវិភាគកម្រងសំណួរ ។

**ជំពូកទី៥ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

ធ្វើការសន្និដ្ឋានទៅលើរាល់គ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្ដល់យោបល់បន្ថែម ។

## ១.៧. គម្រោងស្រាវជ្រាវ

| | | |
|---|---|---|
| ១.គម្រោងស្រាវជ្រាវ | កាលបរិច្ឆេទធ្វើបទបង្ហាញ | ១/៦/២០១៩ |
| ២.បង្កើតឧបករណ៍ស្រាជ្រាវ | ធ្វើបទបង្ហាញ | ៨/៦/២០១៩ |
| ៣.ប្រមូលទិន្នន័យ | ធ្វើបទបង្ហាញ | ១០/ ៦/ ដល់/ ៣១/៧/២០១៩ |
| ៤.សេចក្តីផ្ដើម | ធ្វើបទបង្ហាញ | ១០/៨/២០/១៩ |
| ៥.រំពូកទ្រឹស្តី | ធ្វើបទបង្ហាញ | ៣១/៨/២០១៩ |
| ៦.វិធីសាស្ត្រស្រាវជ្រាវ | ធ្វើបទបង្ហាញ | ១៤/៩/២០១៩ |
| ៧.លទ្ធផលស្រាជ្រាវនិងការវិភាគ | ធ្វើបទបង្ហាញ | ៥/១០/២០១៩ |
| ៨.ការពារនិក្ខេបបទសាកល្បង | ធ្វើបទបង្ហាញ | ១៩/១០/២០១៩ |
| ៩.ការពារនិក្ខេបបទបញ្ចប់ការសិក្សា | ធ្វើបទបង្ហាញ | ២៦/១០/២០១៩ |
| ១០.ប្រគល់និក្ខេបបទបញ្ចប់កាសិក្សា | ធ្វើបទបង្ហាញ | ៣០/១១/២០១៩ |

# ជំពូកទី ២

# រំញកទ្រឹស្តី

# ជំពូកទី២
# រំឭកទ្រឹស្តី

## ២.១.ប្រវត្តិនៃអំណាន
### ២.១.១.និយមន័យនៃអំណាន
#### ២.១.១.១. ដូចម្តេចដែលហៅថា អំណាន?

មានការឲ្យនិយមន័យប្លែកៗគ្នាជាច្រើនទាក់ទងនឹងពាក្យថា អំណាននេះគឺៈ តាមវចនានុក្រមសម្តេចព្រះសង្ឃរាជជួនណាតលោកបានពន្យល់ថា អំណានឬការអាន មានន័យថាការមើលថាតាមអក្សរ។

តាមសៀវភៅភាសាអង់គ្លេស(ArabIdeal)លោកបានពន្យល់ថាៈ អំណាន ឬការអាន គឺសំដៅដល់ការ សម្លឹងមើល និងយល់ដឹងពីន័យសេចក្តី នៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ព។ ការអានគឺជា ការនិយាយឮៗនូវពាក្យដែលបានសរសេរឬបោះពុម្ពផ្សាយ។ ការអាន ឬ អំណាន មានន័យថា ការស្វែងយល់ ពីអត្ថន័យពាក្យពេចន៍ដែលបានបង្កប់ ដែលមិនបានបង្ហាញឲ្យឃើញភ្លាមៗ។ អំណាន មានន័យថាសកម្មភាពនៃការស្វែងយល់ ពីអត្ថន័យ នៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ពផ្សាយ។

#### ២.១.១.២.តើអំណានចាប់កំណើតតាំងពីពេលណា និងតាមរបៀបណាខ្លះ?

អំណានត្រូវបានចាប់កំណើតឡើង តាំងតែពីមានជីវិតមនុស្សមកម្លេះ។ ជាដំបូងមនុស្សអានតាមរយៈកាយវិកា សម្លេង សញ្ញា និង រូបភាពផ្សេងៗ ដូចជា កាយវិកាដេកដើរ ឈរ អង្គុយ សកម្មភាពប្រចាំថ្ងៃរបស់សត្វ ប្រភេទសញ្ញាបាតុភូតធម្មជាតិ ស្នាមជើងមនុស្ស និងសត្វ លាមកសត្វ គុម្ពោធព្រៃដែលសត្វ ឬមនុស្សកាច់សម្គាល់ សូរសម្លេងមនុស្ស សត្វ និងធម្មជាតិជាដើម។ បន្ទាប់មកទៀត មនុស្សបានអាន តាមរយៈអក្សរដែលបានដាប់សម្គាល់នៅលើថ្ម បានចារនៅលើស្លឹករឹត និងស្បែកសត្វ បានសរសេរដោយដៃ នៅលើសន្លឹកសៀវភៅ បានបោះពុម្ព នៅលើសន្លឹកសៀវភៅ ដោយម៉ាស៊ីនអង្គុលីលេខ បានបោះពុម្ព នៅលើសន្លឹកសៀវភៅ ដោយគ្រឿងម៉ាស៊ីនទំនើប បានវាយបញ្ចូល ក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទជាដើម។ អំណានខ្លះ ត្រូវបានគេធ្វើតាមរយៈ

ម៉ាស៊ីនចាប់យករូបភាព វិទ្យុទាក់ទងសម្លេង គំនូរលើក្រដាស ម៉ាស៊ីនថតសម្លេង ឧបករណ៍ទាយ ពីចិត្តសាស្ត្រមនុស្ស ម៉ាស៊ីនឆ្លុះ ....។ល។

### ២.១.១.៣. អំណានមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

តាមការសង្កេត យើងអាចចែកអំណាន ជាបួនប្រភេទគឺ៖

**ក.អំណានក្នុងចិត្តឬអំណានស្ងាត់**

គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹង ពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសម្លេង ឬរលកគំនិតទាំងឡាយ តែក្នុងចិត្តពោលគឺ មិនប្រើប្រាស់សម្លេងខ្លួនឯងចេញមកក្រៅអ្វីឡើយ។

**ខ.អំណានខ្សឹប**

គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹង ពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសម្លេង ឬរលកគំនិតទាំងឡាយ ដោយប្រើប្រាស់ សម្លេងតិចៗឬខ្សឹបៗចេញមកក្រៅ។

**គ.អំណានឮ**

គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹង ពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសម្លេង ឬរលកគំនិតទាំងឡាយ ដោយប្រើប្រាស់ សម្លេងខ្លាំងៗចេញមកក្រៅ។

**ឃ.អំណានស្ទាប**

គឺជាអំណាន ដែលភាគច្រើន ត្រូវបានប្រើប្រាស់ដោយជនពិការភ្នែក។ ពួកគេអាន សៀវភៅ តាមរយៈសញ្ញា អក្សរស្ទាប។ អំណានប្រភេទនេះ គឺអ្នកអានអាចធ្វើតាម រយៈ អំណានស្ងាត់ អំណានខ្សឹប ឬ អំណានឮក៏បាន។

### ២.១.១.៤. ប្រភេទអ្នកអាន

**ក. អ្នកអានលម្អិតឬអ្នកអានវិភាគ**

ជាប្រភេទអ្នកអាន ដែលចូលចិត្តអាន ដោយយកការយល់ គ្រប់ចំណុចសាច់រឿង ឮដែលបានសរសេរ នៅក្នុងសៀវភៅ ឬអត្ថបទណាមួយ។ អ្នកអានប្រភេទនេះ ច្រើនតែ

ជាអ្នកឯកទេស ខាងការស្រាវជ្រាវអ្វីមួយ ព្រោះថាដើម្បីបាន អំណះអំណាងមួយច្បាស់លាស់ លុះត្រាតែគេបានពិនិត្យល្អិតល្អន់ លើអ្វីដែលខ្លួនបានអាន។

**ខ. អ្នកអានត្រួសៗឬអ្នកអានរំលង**

ជាប្រភេទអ្នកអានទាំងឡាយណា ដែលចូលចិត្តអានត្រឹមតែត្រួសៗ ដោយគ្រាន់តែចង់ដឹង ចំណែកណាមួយ ដែលគេចង់ដឹង ឬដែលគេមិនទាន់យល់ប៉ុណ្ណោះ។ ពួកគេច្រើនជាអ្នកអានឯកទេស និងជាអ្នកមិនសូវមានពេលវេលាច្រើនសម្រាប់ការអាន។ គេចង់ប្រើប្រាស់ពេលវេលារបស់ខ្លួនឲ្យមានប្រសិទ្ធិភាពបំផុត។

**គ. អ្នកអានកំសាន្ត**

ជាប្រភេទអ្នកអានដែលបានចាត់ទុកថា ការអាន គឺជាផ្នែកមួយដែលជួយឲ្យអារម្មណ៍របស់គេ បានសប្បាយចិត្ត បានទទួលចំណេះដឹងថ្មីៗ ជាដើម។ គេជាមនុស្សដែលប្រកបដោយភាពជឿជាក់ ទៅលើទំនាក់ទំនងសង្គម។ គេមានគំនិតច្រើន ក្នុងការចែករំលែកក៏ដូចជាការទទួលយកនូវចំណេះដឹងថ្មីៗតាមរយៈសកម្មភាពអំណាន។

**ឃ.អ្នកអានបន្លប់ពេលវេលា**

ជាប្រភេទអ្នកអាន ដែលខ្វះគោលបំណងពិតប្រាកដ អានក៏ព្រោះតែកាលៈទេសៈបង្ខំ អានក៏ព្រោះតែគ្មានអ្វីធ្វើល្អជាងនេះ ឬអានដោយរកគោលបំណង នៃការអានមិនឃើញ។ អ្នកអានប្រភេទនេះ គឺតម្រូវឲ្យមានការលើកទឹកចិត្ត ឲ្យបានច្រើនពីអ្នកឯកទេសអំណាន ឬពីគ្រួសារនិងមិត្តភក្តិរបស់ពួកគេ។

### ២.១.១.៥.ហេតុអ្វីចាំបាច់អានសៀវភៅ?

ការអាន មានសារប្រយោជន៍គ្រប់វេលា មិនថាសម្រាប់ការសិក្សា ការងារ ឬការកម្សាន្តឡើយ។ មិនតែប៉ុណ្ណោះ ការអាន ថែមទាំងជួយបង្កើន ឲ្យខួរក្បាលលោកអ្នកមានភាពរហ័សរហួន ប្រាជ្ញាស្មារតី កាន់តែភ្លឺស្វាង ថែមទៀតផង។ ការអាន អាចជួយឲ្យលោកអ្នក បានស្គាល់ប្រភេទមនុស្ស ហេតុការណ៍នានា ដែលបាន កំពុង ឬនឹងកើតមានឡើង ព្រមទាំងយល់ដឹង ពីពិភពចម្លែកៗ ជាច្រើនទៀត។ ក្រៅពីនេះ អំណាន ឬការអាននៅមានសារសំខាន់ មួយចំនួនទៀត ដូចខាងក្រោម៖

**ក.ដំណើរកំសាន្ត**

នៅពេលដែលលោកអ្នក ចង់ធ្វើដំណើរទៅកាន់ទីណាមួយ ប្រកបដោយជោគជ័យ លោកអ្នកត្រូវតែឆ្លងកាត់ ការអានជាមុន។ តើមានតំបន់ណា ដែលយើងគួរតែ ទៅលេង? តើមានអ្នកណាខ្លះ ដែលអាចនាំយើង ទៅដល់ទីនោះបាន? តើនៅទីនោះ មានអ្វីខ្លះ ដែលគួរឲ្យចាប់អារម្មណ៍ ក្នុងការទស្សនា? ដើម្បីទៅដល់ទីនោះ តើលោកអ្នក ត្រូវឆ្លងកាត់តំបន់ណាខ្លះ? នៅតាមដងផ្លូវដែលលោកអ្នកកំពុងធ្វើដំណើរ លោកអ្នកក៏អាចអាន សេចក្តីណែនាំផ្សេងៗ ដើម្បីទៅឲ្យដល់កន្លែងដែលលោកអ្នកចង់ទៅផងដែរ។

**ខ.ការសិក្សា**

ដើម្បីរៀនឲ្យបានពូកែ ធ្វើលំហាត់ឲ្យបានពិន្ទុល្អ បញ្ចប់កិច្ចការ ដែលលោកគ្រូអ្នកគ្រូ បានដាក់ឲ្យប្រកបដោយជោគជ័យ សិស្ស និស្សិត ត្រូវតែមានភាពស្ទាត់ជំនាញខាងការអានសៀវភៅឬឯកសារនានាដែលមានជាចាំចាច់។

**គ. ការងារ**

ស្ទើរតែនៅគ្រប់ការងារ គឺ សុទ្ធតែត្រូវការអំណាន មិនថាការងាររដ្ឋ ឯកជន ឬអង្គការ សុទ្ធតែត្រូវការអំណាន។ ជំនួយការ លេខាធិការ សុទ្ធតែត្រូវការអំណានយ៉ាងច្រើន ក្នុងការជួយឲ្យការងារ របស់ប្រធានខ្លួន ដំណើរការបានល្អ។ លោកគ្រូអ្នកគ្រូ អ្នកប្រាជ្ញបណ្ឌិត អ្នកស្រាវជ្រាវ មគ្គុទ្ទេសក៍ទេសចរណ៍ សិល្បៈករ អ្នកជំនួញ បណ្ណារក្ខ អ្នកឯកទេសវិទ្យាសាស្ត្រ អ្នកសរសេរកាសែត ឬអ្នកយកព័ត៌មានសុទ្ធសឹងត្រូវការអំណានជាចាំបាច់។

**ឃ. ការចែករំលែក**

តាមរយៈអំណាន គេអាចធ្វើការចែករំលែក ភាពសប្បាយរីករាយ និងចំណេះដឹងឲ្យគ្នា ទៅវិញទៅមក មិនថាតែសម្រាប់មិត្តភក្តិ គ្រួសារ សហគមន៍ ប្រទេសជាតិ ឬក៏សកលលោក។ តាមរយៈអំណាន មនុស្សអាចយល់ចិត្តគ្នា នៅគ្រប់កាលៈទេសៈ។ មនុស្សជំនាន់ថ្មី អាចយល់ដឹងពីគំនិត មនុស្សចាស់ ក៏ដោយសារតែតាមរយៈអំណាននេះឯង។ មនុស្សខ្លះ បានចាត់ទុក ការអានថាជារបៀបនៃការកំសាន្តមួយដ៏ល្អសម្រាប់ពួកគេ។

**ង. ការស្រាវជ្រាវ**

រឿងរ៉ាវក្នុងពិភពលោកនេះ មនុស្សអាចដឹង អាចព្យាករណ៍ទុកមុន ក៏អាស្រ័យដោយអំណាន ពីសិលាចារឹក សាស្ត្រាស្លឹករឹត សាស្ត្រាល្បែង សាស្ត្រាទេស សៀវភៅ គំនូរ គំនិត សម្ភារប្រើប្រាស់ របស់មនុស្ស ក៏ដូចជាបាតុភូតធម្មជាតិ។ មនុស្សសម័យបុរាណ អាចទស្សទាយកម្រិតទឹកភ្លៀង តាមរយៈគំនូស ប្រាប់ឲ្យដឹង តាមរយៈចលនារបស់ពពក ក៏ដូចជាកម្លាំងខ្យល់បក់។

### ២.១.១.៦. តើអំណានគួរចាប់ផ្ដើមនិងបញ្ចប់នៅពេលណា?

អំណាន គឺ មានសារសំខាន់ណាស់ សម្រាប់ទាំងអស់គ្នា មិនថាចាស់ ក្មេង ប្រុស ស្រី អ្នកមាន អ្នកក្រ ស្ដេច រាស្ត្រ មន្ត្រី សេដ្ឋី ប្រភេទជាតិសាសន៍ ឬសាសនាណាឡើយ។ សង្គមបុរាណ ឬសង្គមសម័យទំនើបទេ គឺសុទ្ធតែត្រូវការអំណាន។ អំណានដែលល្អ គួរចាប់ផ្ដើមជាប្រចាំ ចាប់តាំងតែទារកនៅក្នុងផ្ទៃម្ដាយ ឡើងទៅ។ ដើម្បីជួយដល់ ការរីកចម្រើននៃខួរក្បាល លោកអ្នក គួរតែបន្តសកម្មភាពអំណាន ឲ្យបានពេញមួយជីវិតរបស់ខ្លួន។ នៅពេលណា ដែលលោកអ្នកត្រូវការ ខ្យល់បរិសុទ្ធដកដង្ហើម ឬអាហារដែលមានសុខភាព ដើម្បីរស់ដរាបនោះ អំណានក៏ជាផ្នែកមួយ នៃជីវិត ដែលមានសារសំខាន់ ស្រដៀងគ្នានេះដែរ។

### ២.១.១.៧. តើប្រទេសណាខ្លះដែលឲ្យតម្លៃការអានសៀវភៅច្រើនជាងគេ?

តាមបណ្ដាញសារពត៌មានខ្មែរ ជាច្រើនក្នុងរយៈពេលកន្លងមក លោកបានបង្ហាញថា ប្រជាជនដែលឲ្យតម្លៃ លើការអានច្រើនជាងគេ មានដូចជាៈ ជប៉ុន បារាំង អាមេរិក ចិន សាំងហ្គាពួ អូស្ត្រាលី អង់គ្លេស ស៊ុយអែត កាណាដា អាឡឺម៉ង់ ប្រទេសស្វីស ប្រទេសញីវសឺលែន។ ប្រជាជនប្រទេសទាំងអស់នេះ ច្រើនតែអនុវត្តការអានសៀវភៅជាប្រចាំ ច្រើនជម្រុញឲ្យអ្នកគ្រប់រូប អនុវត្តការអានសៀវភៅ និងតែងលើកទឹកចិត្ត ឲ្យមានការតែងនិពន្ធស្នាដៃថ្មីៗជាច្រើន។ មិនតែប៉ុណ្ណោះ ពួកគេថែមទាំងបង្កើត ឲ្យមានការតាំងពិពណ៌ ស្នាដៃនិពន្ធចាស់ថ្មី និងបង្កើតឲ្យមានបណ្ណាល័យ នៅក្នុងគ្រួសារ សាលា សហគមន៍ រហូតដល់បណ្ណាល័យ ថ្នាក់ជាតិថែមទៀតផង។ មានអ្នកប្រាជ្ញដែលពិភពលោក បានស្គាល់គ្រប់គ្នា ពីភាពថ្កុំថ្កើងរបស់លោក តាមរយៈការអាន ដូចជាៈ អ្នកប្រាជ្ញអារីយ៉ូស្សា អ្នកប្រាជ្ញ ញូតុន អ្នកប្រាជ្ញ អារ៉ាហ្គោ ប្រធានាធិបតី នៃលសុន ម៉ាឌីឡា

ប្រធានាធិបតី អាប្រាហាំ លីងកុន មហាត្មៈគន្ធី អ្នកប្រាជ្ញ សូក្រាត អ្នកប្រាជ្ញ ខុងជឺ ព្រះពុទ្ធបរមគ្រូ ព្រះយេស៊ូគ្រីស្ត និង ព្រះមហា ម៉ាត់ ជាដើម។

### ២.១.១.៨. តើប្រជាជនខ្មែរចូលចិត្តអានសៀវភៅក្នុងកម្រិតណា?

#### ក.សម័យបុរាណ

កាលពីសម័យបុរាណ ជាពិសេសនៅក្នុងសម័យអង្គរ បុព្វបុរសខ្មែរមានចំណូលចិត្ត អំណានខ្លាំងណាស់។ កាលណោះ គេឃើញខ្មែរ មានប្រភេទឯកសារសំខាន់ៗជាច្រើន រាយនៅពាសពេញផ្ទៃនគរ ជាពិសេសតាមវត្តអារាម តាមបណ្ណាល័យ ជាដើម តាមជញ្ជាំងប្រាសាទ ដែលមានដូចជា សិលាចារឹក សាស្ត្រាស្លឹករឹត សាស្ត្រាល្បែង សាស្ត្រាទេស។ កាលណោះ ខ្មែរសំបូរទៅដោយអ្នកប្រាជ្ញជាច្រើន ដែលជាព្រះសង្ឃ ជាមន្ត្រី មេទ័ព....។ល។ ខ្មែរកាលសម័យណោះ មាន ភាពស្ទាត់ជំនាញខាង អក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ចម្លាក់ គំនូរ និង ខាងស្ថាបត្យកម្ម។ មានអ្នកប្រាជ្ញជាច្រើនដែលពូកែខាងភាសាខ្មែរ ភាសាបាលី និង សំស្រ្កឹត ក៏ដូចជាភាសាចិន។ ក៏ព្រោះហេតុអ្វី? នោះក៏មកតែខ្មែរកាលជំនាន់នោះ ចូលចិត្តខាងអំណាន។ ចាស់បុរាណច្រើនយកពេលទំនេររបស់ខ្លួនអានសាស្ត្រា និងនិទានរឿងឲ្យក្មេងៗអ្នកស្រុក បានស្តាប់កំសាន្ត។ លោកយកចិត្តទុកដាក់ណាស់ ក្នុងការបណ្តុះបណ្តាល ដល់អ្នកជំនាន់ក្រោយ តាមរយៈការអាន។ ព្រះនាងឥន្ទ្រទេវី ព្រះបាទ អង្គឌួង គឺជាអ្នកប្រាជ្ញដ៏កំពូល ខាងផ្នែកអក្សរសាស្ត្រខ្មែរ។ ដោយសារតែមូលហេតុ ខ្មែរសម័យបុរាណ ចូលចិត្តការអានដូច្នេះហើយ បានជាយើងឃើញ មានសល់អក្សរបុរាណ រាប់មិនអស់នៅលើ សាស្ត្រាស្លឹករឹត ឬជញ្ជាំងប្រាសាទ រហូតមកដល់សព្វថ្ងៃនេះ។

#### ខ.សម័យទំនើប

នៅដើមសម័យកាលទំនើប បើទោះណាជាមាន ចម្បាំងរាំងជល់ខ្លាំងយ៉ាងណាក្តី ក៏ខ្មែរមិនបានភ្លេច ពីរឿងអំណានឡើយ។ នៅសម័យអាណានិគមបារាំង ប្រទេសខ្មែរមានអ្នកប្រាជ្ញ ជាច្រើនដូចជា កវីសន្ធរម៉ុក កវី សុត្តប្រីជាឥន្ទ្រ ព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ។ នៅសម័យសង្គមរាស្ត្រនិយម អ្នកចូលចិត្តអានសៀវភៅជាងគេ យើងឃើញមាន សម្តេចព្រះសង្ឃរាជ ជួន ណាត និងក្រុមរបស់លោក ក្រុមអ្នកស្រាវជ្រាវពុទ្ធសាសន

បណ្ឌិត រួមទាំងប្រជារាស្ត្រ អ្នកប្រាជ្ញ កវីនិពន្ធ និងអ្នកសិល្បករជាច្រើនរូបទៀត។ ចាប់តាំងពីសម័យ ខ្មែរក្រហម ហូតដល់សព្វថ្ងៃ គេសង្កេតឃើញប្រជាជនខ្មែរទូទៅ មិនសូវមានចំណូលចិត្ត អានសៀវភៅប៉ុន្មានទេ។ មនុស្សភាគច្រើន គិតខ្វល់តែរឿង សប្បាយឬការកើតទុក្ខ ខ្វល់តែរឿងក្រពះ សម្រាប់តែមួយពេលៗ ។ ឯអ្នកខ្លះទៀត គិតថា អំណានជារឿង ដែលមិនចាំបាច់សម្រាប់ពួកគេ។

តែទោះជាយ៉ាងណាក្តី ឆ្លងកាត់ការសង្កេតមួយ រយៈពេលថ្មីៗនេះ យើងឃើញថាកូនខ្មែរកំពុងតែ មានការចាប់អារម្មណ៍ លើរឿងអំណាន ឡើងវិញខ្លះៗហើយ។ យើងសង្ឃឹមថា មិនយូរប៉ុន្មាន ខ្មែរនឹងមានការរីកចម្រើន ផ្នែកអំណានខ្លាំងវិញមិនខាន។

### ២.១.១.៩. តើលោកអ្នកគួរជ្រើសរើសសៀវភៅប្រភេទណាដើម្បីអាន?

ការអានសៀវភៅមិនកំណត់ថា ជាសៀវភៅមុខវិជ្ជាណា ភាសាណា ឬអ្នកនិពន្ធណាឡើយ។ ចំនុចសំខាន់ គឺលោកអ្នក គិតតែត្រឹមថា តើសៀវភៅប្រភេទណា ដែលលោកអ្នកចូលចិត្តអាន? ហើយតើសៀវភៅទាំងនោះ គឺជាប្រភេទដែលបានបង្កប់ ទៅដោយការអប់រំ និងគោរពតាមក្រមសីលធម៌ជាតិ និងមិនសូវមានកំហុស លើអក្ខរាវិរុទ្ធដែរឬទេ?

សរុបមកវិញ យើងអាចសន្និដ្ឋានបានថា ការពិតជាមានសារសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា។ ក្នុងនាមយើង ជាកូនខ្មែរ គួរតែខិតខំអាន ស្រាវជ្រាវ និងតែងនិពន្ធឲ្យបានជាប់ជាប្រចាំ ដើម្បីជាការរីកចម្រើន ដល់ខ្លួនយើងផង ក៏ដូចជាការរីកចម្រើន ដល់ប្រទេសជាតិយើងផង។

## ២.២.និយមន័យលទ្ធភាពអំណានដំបូង

លទ្ធភាព គឺសំដៅលើធនធានដែលមានគឺ សមត្ថភាព និងទ្រព្យធន។ សមត្ថភាព គឺ ចំណេះដឹង ចំណេះធ្វើ និងបទពិសោធ ។ ចំណេះដឹង គឺ ខាងអំណានដំបូង រីឯចំណេះធ្វើ និងបទពិសោធជាជំនាញក្នុងការអនុវត្ត ឬបទពិសោធខាងបង្រៀន អំណានដំបូង ។

ទ្រព្យធន គឺសំដៅទៅលើ វត្ថុ ធនធាន សម្បត្តិ ទ្រព្យផ្សេងៗ ទ្រព្យសម្រាប់ប្រើប្រាស់។ អំណាន គឺបើតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត លោកបានពន្យល់ថា៖ អំណាន ឬការអាន មានន័យថា ការមើលថាតាមអក្សរ។ រីឯបើ

តាមសៀវភៅ ភាសាអង់គ្លេស (Arab Ideal) លោកបានពន្យល់ថា អំណាន ឬ ការអានគឺសំដៅដល់ការ សម្លឹងមើល និងយល់ដឹងពីន័យសេចក្តី នៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ព។

ការអានគឺជាការនិយាយឮៗនូវពាក្យដែលបានសរសេរឬបោះពុម្ពផ្សាយ។ ការអាន ឬ អំណាន មានន័យថា ការស្វែងយល់ ពីអត្ថន័យពាក្យពេចន៍ ដែលបានបង្កប់ដែលមិនបានបង្ហាញឲ្យឃើញភ្លាមៗ។

សរុបមក អំណាន មានន័យថា ជាការមើលថាតាមអក្សរ ឬសកម្មភាព នៃការស្វែងយល់ ពីអត្ថន័យ នៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ពផ្សាយ។

ដំបូង គឺ ជាសំដៅលើពាក្យថា ជាបឋម , ជាខាងដើម, មុន, ទីមួយ។

អំណានដំបូងទីនេះ សំដៅលើការចាប់ផ្តើមរៀនអានអក្សរលើកទីមួយ របស់កុមារតូចៗចាប់ពីពួកគេបានរៀនចប់មត្តេយ្យសិក្សា ដែលផ្តោតសំខាន់លើដំណាក់កាល ៧ រួមមាន ការស្គាល់សូរ ស្គាល់តួអក្សរ ចេះអានព្យាង្គ និងពាក្យ ចេះវាក្យសព្ទ ចេះអានល្បះ ចេះអានអត្ថបទខ្លី និងការសរសេរ។

ដូចនេះអត្ថន័យរបស់ប្រធានបទ ៖ លទ្ធភាពនៃការអនុវត្តអំណានដំបូង បានសេចក្តីថា ទ្រព្យធនដែលមានសម្រាប់ប្រើប្រាស់ និង សមត្ថភាពដែលមានទាំងចំណេះដឹង ចំណេះធ្វើ និងបទពិសោធឬជំនាញក្នុងការបង្ហាត់បង្រៀន ដើម្បីយកមកអនុវត្តពន្យល់ណែនាំ អំពីការរៀនអានអក្សរដំបូងបំផុត របស់កុមារតូចៗដែលបានរៀននៅមត្តេយ្យ និងឆ្លងផុតមត្តេយ្យសិក្សា ហើយការបង្រៀននេះទៀតសោធត្រូវផ្តោតសំខាន់ទៅលើ ដំណាក់កាល ៧ រួមមាន ការស្គាល់សូរ ស្គាល់តួអក្សរ ចេះអានព្យាង្គនិងចេះពាក្យវាក្យស័ព្ទ អានល្បះ អានអត្ថបទខ្លី និងការសរសេរ។

## ២.៣.ការបង្រៀនអំណានដំបូង

### ២.៣.១.ចំណិនទាំង៥នៃអំណាន

#### ក. ការស្គាល់សូរ

ការស្គាល់សូរ គឺសំដៅលើការបង្រៀនដើម្បីជួយឲ្យសិស្សមានសមត្ថភាពកំណត់ប្រើប្រាស់ និងញែកសូរក្នុងពាក្យ។

ឧទាហរណ៍៖ សិស្សប្រាប់តួអក្សរក្នុងពាក្យ «កា» (ក និង ស្រៈអា ា) តាមរយៈរូបភាពឬស្តាប់គ្រូពន្យល់ ។

**ខ.ការស្គាល់តួអក្សរ និងសូរ**

ការស្គាល់តួអក្សរ គឺសំដៅដល់ការបង្រៀនដែលជួយដល់អ្នកអាន(សិស្ស)យល់ និងអនុវត្តចំណេះដឹងស្តីអំពីទំនាក់ទំនងរវាងតួអក្សរ និងសូរ ។

ឧទាហរណ៍៖ សិស្សអាចប្រាប់គ្រូថារូបភាពនៃពាក្យ **កា** មានសូរតួអក្សរ **ក**

**គ.ការចេះអានស្ទាត់**

ការចេះអានស្ទាត់ គឺសំដៅលើការបង្រៀនដែលជួយពង្រឹងដល់សមត្ថភាពអានឮ ដោយមានល្បឿនច្បាស់លាស់ និងការបង្ហាញគំនិតត្រឹមត្រូវ ។

ឧទាហរណ៍៖ សិស្សអាចអានពាក្យ ឃ្លា ឬល្បះបានត្រឹមត្រូវ ។

**ឃ.ការចេះវាក្យសព្ទ**

ការចេះអានវាក្យស័ព្ទ គឺសំដៅលើការបង្រៀនដើម្បីបង្កឲ្យមានចំណេះដឹងស្តីពីពាក្យ។ រាប់ទាំងពាក្យប្រើប្រាស់ផ្ទាល់ខ្លួន និងពាក្យសរសេរដូចជាតាមរយៈការស្គាល់ពាក្យដោយការឲ្យ ឃើញ មើល និងអាន ។

ឧទាហរណ៍៖ សិស្សអាចអានពាក្យ **ចំណាំ** ដែលប្រើញឹកញាប់ដែលគ្រូសរសេរលើក្តារខៀន ឬបង្ហាញប័ណ្ណពាក្យ ។

**ង.ការអានដើម្បីយល់ន័យ**

ការអានដើម្បីយល់ន័យ គឺសំដៅទៅលើការបង្រៀនដែលធ្វើឲ្យសិស្សមានសមត្ថភាពចូលរួម និងបញ្ចេញន័យដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន។

ឧទាហរណ៍៖ សិស្សអាចប្រាប់គ្រូអំពីអត្ថន័យនៃល្បះដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេផ្ទាល់។

### ២.៣.២.សមត្ថភាពគោលនាំទ ៧ នៃអំណានដំបូង

**ក. ការស្គាល់សូរអក្សរថ្មី**

ការស្គាល់សូរ គឺជាសមត្ថភាពស្ដាប់សូរ កំណត់សូរ និងប្រើប្រាស់សូរក្នុងភាសានិយាយ ។ ការស្គាល់សូរមានសារៈសំខាន់ក្នុងការជួយឲ្យសិស្សចេះផ្សំប្រកប និងបំបែកសូរដើម្បីចេះអាន និងចេះសរសេរ ។

សកម្មភាពក្នុងការបង្រៀន "ការស្គាល់សូរអក្សរថ្មី" មានសកម្មភាពរងពីរសំខាន់ៗ

**ក.១ ការបង្រៀនសកម្មភាពរងសំខាន់ទី១គឺ៖**

ល្បែងទស្សន៍ទាយ៖ គ្រូបំផុសសំណួរទាក់ទងនឹងសកម្មភាព វត្ថុជាក់ស្ដែង រូបភាព ឬដោយការពណ៌នាដើម្បីឱ្យសិស្ស៖ រកពាក្យ ថាតាមពាក្យគ្រូ ប្រាប់សូរ។

**ក.២.ការបង្រៀនសកម្មភាពរងសំខាន់ទី២គឺ៖**

ល្បែងបាទ ចាស និងទេ៖ គ្រូពន្យល់សញ្ញា បាទ/ចាស និង ទេ រួចពន្យល់អំពីការលេងល្បែងគឺ គ្រូពន្យល់សិស្សថា គ្រូនឹងហៅពាក្យមួយ។ ប្រសិនបើពាក្យនោះមានសូរ អែ ឬដាក់ស្រៈ ែ សិស្សត្រូវធ្វើសញ្ញា "បាទ ឬចាស" ។ ប្រសិនបើពាក្យនោះមិនមានសូរ អែ ទេ សិស្សធ្វើសញ្ញា "ទេ" ។ គ្រូឱ្យសិស្សក្រោកឈរ។

**ខ.ការស្គាល់តួអក្សរថ្មី**

ការស្គាល់តួអក្សរថ្មី គឺជាទំនាក់ទំនងរវាងតួអក្សរនិងសូរ។ សារៈសំខាន់ឲ្យសិស្សចេះអានផ្សំប្រកបអក្សរដើម្បីអានព្យាង្គ និងពាក្យ។

សកម្មភាពក្នុងការបង្រៀន "ការស្គាល់តួអក្សរថ្មី" មានសកម្មភាពរង ពីរ សំខាន់ៗ គឺ៖

**ខ.១. ការបង្ហាញតួអក្សរថ្មី**

1. គ្រូសរសេរតួអក្សរថ្មីឱ្យធំ នៅលើក្ដារខៀន និងអានតួអក្សរនោះ
2. គ្រូបង្ហាញប័ណ្ណអក្សររូបភាព និងប្រាប់អំពីសូរនៃតួអក្សរនោះ
3. គ្រូធ្វើកាយវិការតាមរូប ហើយនិយាយសូរនៃតួអក្សរនោះ។ សិស្សធ្វើកាយវិការតាមគ្រូ ហើយនិយាយសូរនៃតួអក្សរនោះ
4. គ្រូឱ្យសិស្សអានតួអក្សរនោះម្ដងទៀត ដោយចង្អុលតួអក្សរលើក្ដារខៀន
5. គ្រូឱ្យសិស្សបើកសៀវភៅជំនួយសិស្ស ត្រង់មេរៀនតួអក្សរថ្មីជាបុគ្គលរួចលើកបង្ហាញគ្រូ ដោយចង្អុលឱ្យចំតួអក្សរថ្មីនោះ

6. គ្រូដើរជុំវិញពិនិត្យមើលសកម្មភាពរបស់សិស្ស និងជួយសិស្សដែលមានការលំបាក ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

**ខ.២. ការបង្ហាញតួអក្សរ និងការធ្វើកាយវិការ**

1. គ្រូបង្ហាញប័ណ្ណអក្សររូបភាពដែលសិស្សបានរៀនរួច និងរំឭកកាយវិការឡើងវិញ
2. គ្រូលើកប័ណ្ណអក្សររូបភាពថ្មីបង្ហាញសិស្ស និងនាំឱ្យសិស្សធ្វើកាយវិការ
3. គ្រូលើកប័ណ្ណអក្សររូបភាពទាំងនោះ មិនតាមលំដាប់ ហើយឱ្យសិស្សធ្វើកាយវិការ និងនិយាយពាក្យទាំងនោះ
4. គ្រូលើកអក្សរចល័តបង្ហាញម្ដងមួយៗ ហើយឱ្យសិស្សថាតួអក្សរនោះ និងធ្វើកាយវិការ។

**គ.ការអានព្យាង្គ**

ការអានព្យាង្គនិងពាក្យ គឺជាដំណាក់កាលដំបូងដែលសិស្សមានឱកាសរៀនផ្សំប្រកបជាមួយតួអក្សរដទៃទៀតដែលរៀនរួច ។ សារៈសំខាន់ដើម្បីជួយសិស្សចេះភ្ជាប់តួអក្សរទៅសូរ និងហាត់អានដោយផ្សំប្រកបដែលអាចជួយកុមារឲ្យអានស្ទាត់ និងអានយល់ន័យ ។

សកម្មភាពក្នុងការបង្រៀន "ការអានព្យាង្គ" មានសកម្មភាពរងពីរសំខាន់ៗគឺៈ

**គ.១. ការប្រកបសូរដោយប្រើដៃ**

1. គ្រូ ប្រកបសូរ ដៃ ដោយធ្វើដៃក្នុងខ្យល់បង្ហាញសិស្ស
2. គ្រូ និងសិស្ស ប្រកបសូរ កៃ ដោយធ្វើដៃក្នុងខ្យល់
3. សិស្ស ប្រកបសូរ ចៃ ខៃ ដៃ កៃ ដោយធ្វើដៃក្នុងខ្យល់។

**គ.២. ការអានព្យាង្គ**

1. គ្រូធ្វើជាគំរូដោយប្រើអក្សរចល័ត ក ប្រកបនឹងស្រៈ ៃ អានថា កៃ
2. គ្រូ និងសិស្សធ្វើ គ្រូប្រើអក្សរចល័ត ខ ច ឆ ផ្សំជាមួយស្រៈ ៃ ម្ដងមួយៗ ឱ្យសិស្សអានជាមួយគ្រូ ខៃ ចៃ ឆៃ

3. គ្រូសរសេរព្យាង្គ កែ ខែ ចៃ ឆៃ លើក្តារខៀន។ គ្រូគួរប្រើដីសពណ៌ (ខៀវ សម្រាប់សរសេរព្យញ្ជនៈ)
4. គ្រូ និងសិស្សអាន ដោយប្រកបព្យាង្គទាំងនោះនៅលើក្តារខៀនទាំងអស់គ្នា
5. គ្រូឱ្យសិស្សអានព្យាង្គទាំងបួនក្នុងតារាង ដែលមានក្នុងសៀវភៅជំនួយ កែ ខែ ចៃ ឆៃ ដោយប្រកបជាដៃគូ
6. គ្រូឱ្យសិស្សអានព្យាង្គ កា ដល់ កែ ក្នុងសៀវភៅជំនួយសិស្សជាដៃគូដោយប្រកប។

**ឃ.ការពាក្យវាក្យស័ព្ទ**

ការចេះវាក្យសព្ទ គឺជាការបង្រៀនសំដៅដល់ឲ្យសិស្សចេះអានពាក្យថ្មី យល់ន័យរបស់ពាក្យ និងដឹងអំពីរបៀបប្រើប្រាស់ពាក្យនោះ ។ សារៈសំខាន់នៃការចេះវាក្យសព្ទ គឺធ្វើឲ្យសិស្សរៀនពាក្យថ្មីបានល្អប្រសើរ កាលណាគ្រូបង្រៀនពួកគេអំពីនិយមន័យរបស់ពាក្យតាមបែបដែលសិស្សងាយយល់ ហើយយកពាក្យនោះទៅហាត់តែងល្បះបាន ។

សកម្មភាពក្នុងការបង្រៀន "ការអានពាក្យ" មានសកម្មភាពរងពីរសំខាន់ៗគឺៈ

**ឃ.១. វាក្យសព្ទ**

1. គ្រូ ពន្យល់ន័យនៃពាក្យ និងប្រើប្រាស់ពាក្យក្នុងល្បះ
2. គ្រូ និងសិស្ស បង្កើតល្បះជាមួយពាក្យថ្មីទាំងអស់គ្នា
3. សិស្ស បង្កើតល្បះជាដៃគូ។

**ឃ.២. ការភ្ជាប់ពាក្យ នឹងរូបភាព**

1. គ្រូសួរសិស្សដើម្បីបញ្ជាក់ពីរូបភាព។ នេះជារូបភាពអ្វី?
2. គ្រូអានពាក្យក្នុងសៀវភៅជំនួយសិស្ស និងភ្ជាប់ពាក្យទៅនឹងរូបភាពនោះ
3. គ្រូ និងសិស្សអានពាក្យបន្ទាប់រួមគ្នា ហើយភ្ជាប់ពាក្យទៅនឹងរូបភាពឱ្យបានត្រឹមត្រូវ
4. សិស្សអានពាក្យ បន្ទាប់មកភ្ជាប់ពាក្យទៅនឹងរូបភាពឱ្យបានត្រឹមត្រូវដោយខ្លួនឯង។

**ង. ការអានល្បះ**

ការចេះអានល្បះមានសារៈសំខាន់ គឺដើម្បីជួយឲ្យសិស្សមានបំណិនអានស្ទាត់ និងយល់ន័យ ហើយនិងដើម្បីឲ្យសិស្សត្រៀមបានល្អក្នុងការអានអត្ថបទ ។

សកម្មភាពបង្រៀនល្បះ៖

1. គ្រូចម្លងល្បះដាក់លើក្ដារខៀន
2. គ្រូអានល្បះជាគំរូ
3. គ្រូនាំសិស្សញែកពាក្យក្នុងល្បះដោយសួរថា តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?
4. គ្រូឲ្យសិស្សអានល្បះលើក្ដាខៀន
5. គ្រូឲ្យសិស្សអានល្បះជាដៃគូរក្នុងសៀវភៅសិក្សាគោល
6. គ្រូពន្យល់ ពាក្យពិបាកនិងនាំសិស្សពិភាក្សាអត្ថន័យនៃល្បះដោយផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**ច. ការអានអត្ថបទខ្លី**

ការចេះអានអត្ថបទខ្លី គឺជាការអានរឿងខ្លីៗដោយប្រើពាក្យពេចន៍ងាយៗដែលកុមារបានរៀនរួច ។ សារៈសំខាន់ គឺសិស្សចេះអានស្ទាត់ (អានក្នុងល្បឿន សមស្រប ត្រឹមត្រូវ និងលើកដាក់សំឡេងតាមឃ្លាល្បះ) ។ លើសពីនេះ សិស្សយល់ន័យអត្ថបទដោយអាចឆ្លើយសំណួរចេះបកស្រាយ និងផ្ដល់ព័ត៌មាន ។ល ។

សកម្មភាពក្នុងការបង្រៀន "ការអានអត្ថបទខ្លី" មានបីជំហានសំខាន់ៗគឺ៖

**ច.១. មុនពេលអាន**

- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងប្រាប់ចំណងជើងអត្ថបទ
- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា៖ តើរឿងនេះនិយាយពីអ្វី?

**ច.២. អំឡុងពេលអាន**

- គ្រូអានរឿងទាំងមូលដោយល្បឿនសមស្រប ដោយលើកដាក់សម្លេងតាមឃ្លាល្បះក្នុងសាច់រឿង
- គ្រូ និងសិស្សអានទាំងអស់គ្នា (ពេលជាមួយគ្នា)
- គ្រូឱ្យសិស្សហ្វឹកហាត់អានជាដៃគូ

**ច.៣. ក្រោយពេលអាន**

- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស ពីមុនពេលអាន
- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត
- គ្រូឱ្យសិស្សឆ្លើយសំណួរជាបុគ្គល
- គ្រូសម្របសម្រួលចម្លើយសិស្ស

**ឆ.ការសរសេរ និងឃ្លា**

ការសរសេរ គឺមានទំនាក់ទំនងជាមួយនឹងការអាន កាលណាកុមារកាន់តែពូកែអាន ពួកគេក៏កាន់តែពូកែសរសេរផងដែរ ព្រោះវាជំរុញឲ្យមានការយល់ដឹងសូរភ្ជាប់អំពីអក្សរ ដើម្បីសរសេរតួអក្សរព្យាង្គ និងពាក្យ ។ ការសរសេរជួយឲ្យសិស្សអានបានល្អក្នុងការគោរព ឃ្លា ល្បះ និងសញ្ញាសម្គ័ន្ធនានា (សិស្សដែលសរសេរបានល្អក៏អានបានល្អដែរ)។

សកម្មភាពក្នុងការបង្រៀន "ការសរសេរ" មាន ពីរ ជំហានសំខាន់ៗគឺ៖

**ឆ.១. ការសរសេរតួស្រះ**

1. គ្រូសរសេរស្រះ ◌ៃ ឱ្យធំលើក្តារខៀន ដោយប្រាប់ពីចលនានៃអក្សរ
2. គ្រូ និងសិស្ស សរសេរស្រះ ◌ៃ ក្នុងខ្យល់( គ្រូបែខ្នងទៅសិស្ស)
3. សិស្សគូសស្រះ ◌ៃ ដោយប្រើចង្អុលដៃ តាមលំនាំក្នុងសៀវភៅជំនួយសិស្ស
4. សិស្ស សរសេរស្រះ ◌ៃ លើក្តារឆ្នួន

**ឆ.២. ការសរសេរព្យាង្គ**

1. គ្រូណែនាំសិស្សដោយបើកសៀវភៅជំនួយសិស្សត្រង់មេរៀនស្រះ ◌ៃ (ឧទាហរណ៍៖ ទំព័រ ៣៧) បង្ហាញ
2. គ្រូពន្យល់ដោយចង្អុលព្យញ្ជនៈ ក ខ ច ឆ ក្នុងតារាង ផ្សំជាមួយស្រះ ◌ៃ នៅផ្នែកខាងចុងម្តងមួយៗ ហើយសរសេរចូលក្នុងសៀវភៅកិច្ចការ
3. គ្រូឱ្យសិស្សបើកសៀវភៅជំនួយសិស្សត្រង់មេរៀនស្រះ ◌ៃ និងសៀវភៅកិច្ចការ
4. គ្រូឱ្យសិស្សចម្លងចូលក្នុងសៀវភៅកិច្ចការ។

# ជំពូកទី ៣
# វិធីសាស្ត្រនៃ
# ការស្រាវជ្រាវ

# ជំពូកទី ៣
# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១. ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យដែលបានយកមកវិភាគ ដើម្បីស្វែងយល់ពីលទ្ធភាពនៃការអនុវត្តអំណានដំបូងនៅសាលាបឋមសិក្សា នៅតាមខេត្ត ស្រុក និងសាលាដែលជាគោលដៅនៃការស្រាវជ្រាវលើប្រធានបទនេះ ។

## ៣.២. ទីកន្លែងសិក្សាស្រាវជ្រាវ

ការសិក្សានេះ ជ្រើសរើសយក ខេត្តតាកែវ ដែលជាទីតាំងសម្រាប់ធ្វើការប្រមូលទិន្នន័យ។ ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ខាងលើ ការស្រាវជ្រាវនេះមានវត្ថុបំណងសំខាន់ៗ មួយ គឺ៖ (១) លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅសាលារៀនបឋមសិក្សា ដោយផ្អែកទៅលើកត្តា ភេទ កម្រិតនៃការអប់រំ ប្រភេទសមាជិក កម្រិតវិជ្ជាជីវៈ និងបទពិសោធន៍។ ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើនេះ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ ព្រមទាំងរួមផ្សំជាមួយនឹងព័ត៌មានដែលបានមកពីការអង្កេត និងការសម្ភាសផ្ទាល់របស់អ្នកស្រាវជ្រាវ ជាមួយនឹងថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំស្រុក ថ្នាក់ដឹកនាំសាលារៀន និងនាយកសាលារៀននីមួយៗដែលបានជ្រើសរើសទាំងអស់នោះ ។

## ៣.៣. ការជ្រើសរើសសំណាក

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែល មានការចូលរួមពីភាគីពាក់ព័ន្ធដូចជា ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត ថ្នាក់ដឹកនាំក្រុង/ស្រុក នាយកសាលា និងលោកគ្រូអ្នកគ្រូ ។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមានថ្នាក់ដឹកនាំមន្ទីរអប់រំ ០១នាក់ នាយកសាលា ១០ នាក់ និងលោកគ្រូ-អ្នកគ្រូ ៥៥នាក់ នៅខេត្តតាកែវដែលយកតែស្រុកចំនួនបីតែប៉ុណ្ណោះ ។ សូមបញ្ជាក់ផងដែរ ខេត្តតាកែវមានស្រុកចំនួន ១១ និងសាលាបឋមសិក្សាចំនួន ៣៨២ ស្មើនឹង ៧១ សាលាកម្រង។ ក្នុងនេះផងដែរ អ្នកស្រាវជ្រាវបានជ្រើសរើសភាគសំណាកចំនួន ៣០% មកធ្វើការស្រាវ

ជ្រាវ។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវរើសយកភាគសំណាកខាងលើមកធ្វើការស្រាវជ្រាវ គឺដើម្បីចង់ដឹងអំពីលទ្ធភាពនៃការអនុវត្តអំណានដំបូងរបស់ថ្នាក់ដឹកនាំមន្ទីរ ស្រុក នាយក និងលោកគ្រូអ្នកគ្រូនៅខេត្តតាកែវ អាចមានលទ្ធភាព និងសមត្ថភាពដូចទៅនឹងការអនុវត្តអំណានដំបូងនៅខេត្តសៀមរាប និងកំពុងធំដែលក្រសួងអប់រំ ព្រមទាំងអង្គការ មិនមែនរដ្ឋាភិបាលបាននឹងកំពុងជួយគាំទ្រដល់ លោកគ្រូ អ្នកគ្រូហើយទទួលបានលទ្ធលផលសិស្សអានអានបាន ៦៨% (EGRA 2017-2018) គួរឲ្យកោតសរសើរ។ រីឯសំណាកដែលត្រូវជ្រើសរើសមកបំពេញកម្រងសំណួរ និងសម្ភាស គឺយើងធ្វើការជ្រើសរើសតាមទំហំ និងស្ថានភាពជាក់ស្តែង ៣០% នៃខេត្តទាំងមូល។ យើងបានធ្វើការណាត់ជួបភាគសំណាកទាំងអស់ជាមុនទៅតាមពេលវេលាដែលបានកំណត់។

## ៣.៤. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរដែលជា លក្ខណៈកម្រិតចម្លើយ និងសំណួរទម្រង់បើកសម្រាប់ថ្នាក់ដឹកនាំមន្ទីរ ប្រធានការិយាល័យស្រុក នាយក និងលោកគ្រូ អ្នកគ្រូ ។ កម្រងសំណួរមានបួនប្រភេទ ត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យរួមមាន ៖

កម្រងសំណួរសម្រាប់ថ្នក់ាដឹកនាំមន្ទីរ ថ្នាក់ដឹកនាំស្រុក នាយកសាលា និងសម្រាប់ លោកគ្រូ-អ្នកគ្រូ។ ក្នុងការសិក្សាស្រាវជ្រាវនេះ យើងប្រើប្រាស់កម្រងសំណួរចំនួន ០១ ច្បាប់ សម្រាប់ថ្នាក់ដឹកនាំមន្ទីរ ០៣ច្បាប់សម្រាប់ស្រុក ១០ច្បាប់សម្រាប់នាយក និង ៥៥ ច្បាប់ សម្រាប់គ្រូបង្រៀន ។ ក្នុងការបង្កើតកម្រងសំណួរនេះយើងខ្ញុំបានរៀបចំតាក់តែង ខ្លឹមសារ កម្រងសំណួរ ស្របនឹងវិធីសាស្ត្របង្រៀនអំណានដំបូងដែលបានដកស្រង់ចេញពីសៀវភៅណែនាំគ្រូបង្រៀនថ្នាក់ទី ១ (ភាគ១ ភាគ២) ស្តីអំពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ ដើម្បីវាស់សមត្ថភាពលោកគ្រូអ្នកគ្រូប្រៀបធៀបនឹងការបង្រៀនរបស់ពួកគាត់ ។

## ៣.៥. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ

### ៣.៥.១. កម្រងសំណួរសម្រាប់ថ្នាក់ដឹកនាំមន្ទីរ

កម្រងសំណួរសម្រាប់ថ្នាក់ដឹកនាំមន្ទីរ បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍ ៖

**ក. កម្រងសំណួរទម្រង់បិទបែងចែកជាពីរផ្នែកគឺ៖**

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៣សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ប្រភេទសមាជិក អំពីកម្រិតវិជ្ជាជីវៈ និងបទពិសោធការងារអ្នកបំពេញកម្រងសំណួរ ។
- ផ្នែកទី២ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីលទ្ធភាព ចំណេះដឹង និងសមត្ថភាពថ្នាក់ដឹកនាំមន្ទីរអំពីអំណានដំបូង ថាតើមានលទ្ធភាពដល់កម្រិតណា។

**ខ. កម្រងសំណួរសម្រាប់សម្ភាស** គឺចង់វាស់ស្ទង់មតិរបស់លោកថ្នាក់ដឹកនាំមន្ទីរអំពីលទ្ធភាពនៃការអនុវត្តអំណានដំបូង ។

### ៣.៥.២. កម្រងសំណួរសម្រាប់ការិយាល័យស្រុក

កម្រងសំណួរសម្រាប់ស្រុក បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍ ៖

**ក. កម្រងសំណួរទម្រង់បិទបែងចែកជា ពីរ ផ្នែកគឺ៖**

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន ៣ សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ប្រភេទសមាជិក អំពីកម្រិតវិជ្ជាជីវៈ និងបទពិសោធការងារអ្នកបំពេញកម្រងសំណួរ ។
- ផ្នែកទី២ លទ្ធភាពនៃការអនុវត្តកាអំណានដំបូងនៅបឋមសិក្សា ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញ ពីចំណុចមួយចំនួនអំពីលទ្ធភាពនៃការអនុវត្តអំណានដំបូង តាមសាលារៀន ថាតើមានលទ្ធភាពនិងសមត្ថភាពដល់កម្រិតណា ។

**ខ. កម្រងសំណួរសម្រាប់សម្ភាស** គឺចង់វាស់ស្ទង់មតិរបស់លោកថ្នាក់ដឹកនាំស្រុក ទាក់ទងនឹងការដាក់ឲ្យអនុវត្តអំណានដំបូង ។

### ៣.៥.៣. កម្រងសំណួរសម្រាប់នាយក

កម្រងសំណួរសម្រាប់សិស្ស បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និង កម្រងសំណួរសម្រាប់សម្ភាសន៍ ៖

**ក. កម្រងសំណួរទម្រង់បិទចែកជាពីរផ្នែកគឺ៖**

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន ៤ សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ អាយុ កម្រិតវប្បធម៌ចំនួនគ្រូ ។
- ផ្នែកទី២ លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា ផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញ ពីចំណុចមួយចំនួននៃចំណេះដឹងអំពីការអនុវត្តអំណានដំបូងនៅបឋមសិក្សា ថាតើមានលទ្ធភាពដល់កម្រិតណា ទាក់ទងនឹងធនធានដែលសាលាមានស្រាប់ ។

**ខ. កម្រងសំណួរសម្រាប់សម្ភាស** គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីចំណេះដឹងនៃការអនុវត្តអំណានដំបូង។

### ៣.៥.៤. កម្រងសំណួរសម្រាប់សម្ភាសលោកគ្រូអ្នកគ្រូ

កម្រងសំណួរសម្រាប់គ្រូ ត្រូវបែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និង កម្រងសំណួរសម្រាប់សម្ភាស ៖

**ក. កម្រងសំណួរទម្រង់បិទចែកជាពីរផ្នែកគឺ៖**

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន ៥ សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ប្រភេទសមាជិក អំពីកម្រិតវិជ្ជាជីវៈ និងបទពិសោធន៍ការងារអ្នកបំពេញកម្រងសំណួរ ។
- ផ្នែកទី២ លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា ក្នុងផ្នែក នេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញ ពីចំណុចមួយចំនួនគឺ លទ្ធភាពនៃការអនុវត្តអំណានដំបូងនិងវិធីសាស្រ្តបង្រៀនអំណានដំបូងរបស់ លោកគ្រូអ្នកគ្រូនៅតាមសាលាគោលដៅដែលបានចុះប្រមូលទិន្នន័យស្រាវជ្រាវ ថាតើ

មានលទ្ធភាពដល់កម្រិតណាទាក់ទងនឹងធនធាន សមត្ថភាព មានចំណេះដឹង ចំណេះធ្វើ និងបទពិសោធរបស់លោកគ្រូអ្នកគ្រូ ក្នុងការបង្រៀន។

**ខ. កម្រងសំណួរសម្រាប់សម្ភាស** គឺចង់វាស់ស្ទង់មតិរបស់លោកគ្រូអ្នកគ្រូពីវិធីសាស្ត្របង្រៀនអំណាន ធៀបទៅនឹងសៀវភៅណែនាំពីរបៀបបង្រៀនដែលមាននៅក្នុងកញ្ចប់សម្ភារៈអំណានដំបូងរបស់ក្រសួងអប់រំ។

## ៣.៦. ដំណើរការប្រមូលទិន្នន័យ

មុនពេលផ្តល់កម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងអ្នកស្រាវជ្រាវបានធ្វើលិខិតស្នើសុំចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ បន្ទាប់មកយកទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រួចមកអ្នកស្រាវជ្រាវ ក៏បានយកលិខិតស្នើសុំនោះទៅប្រគល់ជូនលោកប្រធានការិយាល័យអប់រំក្រុង និងស្រុក ដើម្បីសុំការអនុញ្ញាតក្នុងការចុះប្រមូលទិន្នន័យព្រមទាំងសម្ភាសលើសំណាកដែលមានថ្នាក់ដឹកនាំមន្ទីរផ្ទាល់ ប្រធានការិយាល័យស្រុក នាយកសាលា និងលោកគ្រូអ្នកគ្រូនៅតាមសាលាគោលដៅ ។ បន្ទាប់មកទៀតអ្នកស្រាវជ្រាវក៏បានផ្តល់កម្រង សំណួរដល់ ថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំស្រុក លោកនាយក និងលោកគ្រូអ្នកគ្រូ ដើម្បីបំពេញ និងធ្វើការសម្ភាសផ្ទាល់ ។

## ៣.៧. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើ ប្រាស់កម្មវិធី SPSS ដើម្បីបញ្ចូល និងវិភាគទិន្នន័យ និងប្រើកម្មវិធី Ms Excel ដើម្បីបង្ហាញតារាង និងតារាងក្រាហ្វិក ក្នុងការវិភាគបែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតចម្លើយនៃ សកម្មភាពនានាដែលពាក់ព័ន្ធលទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា ដោយគិតជាចំនួនធម្យម និងភាគរយ ។ រីឯសំណួរបើកវិញជាសំណួរបែបគុណវិស័យ យើងខ្ញុំវិភាគដោយប្រើប្រាស់កម្មវិធី SPSS និង Ms Word ។ ដូច្នេះនៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគ គឺ

អាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើវាជាប្រភេទកម្រងសំណួរបើក ឬកម្រងសំណួរបិទ។

## ៣.៨. ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបានផ្ដល់ដំណឹងបន្តទៅដល់មូលដ្ឋានសាលារៀន និងថ្នាក់ដឹកនាំក្រុង/ស្រុកគោលដៅ ក្នុងការសុំជួបសម្ភាសជាមួយ ប្រធានការិយាល័យក្រុង/ស្រុក នាយកសាលា និងគ្រូ ។ គ្រប់ពេលការជួបសម្ភាសជាមួយ ថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំក្រុង/ស្រុក នាយក និងលោកគ្រូអ្នកគ្រូ យើងតែងតែជម្រាប ពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវ ដែលធានាអះអាងរក្សានូវរាល់ការសម្ងាត់ចំពោះគ្រប់រាល់ចម្លើយរបស់ពួកគាត់ដោយមិនបានបង្ហាញពីឈ្មោះរបស់អ្នកចូលរួមឆ្លើយពិតប្រាកដនោះទេ ដើម្បីទាមទារឱ្យបានចម្លើយដែលពិតប្រាកដនិងមានប្រសិទ្ធភាព។

# ផ្នែកទី ៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូកទី ៤
# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងបង្ហាញនូវលទ្ធផលដែលប្រមូលបាន ទៅតាម ខ្លឹមសារនៃកម្រងសំណួរម្ដងមួយៗ តាមរយៈតារាង និងក្រាហ្វិកហើយ និងធ្វើការបកស្រាយ ធៀបនឹងខ្លឹមសារដែលមាននៅក្នុងសៀវភៅណែនាំស្ដីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅ។

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.១. អ្នកចូលរួមក្នុងការផ្ដល់ព័ត៌មានក្នុងការស្រាវជ្រាវ

ក្រោយពេលបូកសរុបទិន្នន័យតាមគោលដៅ ដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងឆ្លើយសំណួរសម្ភាសរួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមឆ្លើយក្នុងការផ្ដល់ព័ត៌មាន សរុបមានចំនួន ៦៩នាក់ ស្រី ២៨នាក់ ដែលក្នុងនោះ មានថ្នាក់ដឹកនាំមន្ទីរ ០១នាក់ ថ្នាក់ដឹកនាស្រុក ០៣នាក់ នាយកសាលា ១០នាក់ និងគ្រូបង្រៀន ៥៥ នាក់ ស្រី ២៨នាក់ ។

**តារាងទី១ ៖ ចំនួនអ្នកចូលរួមផ្ដល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ**

| អ្នកចូលរួមឆ្លើយសំណួរ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្តតាកែវ | ០១នាក់ | ០០នាក់ | ០១នាក់ |
| ថ្នាកើដឹកនាំការិយាល័យស្រុក | ០៣នាក់ | ០០នាក់ | ០៣នាក់ |
| នាយកសាលា | ១០នាក់ | ០០នាក់ | ១០នាក់ |
| គ្រូបង្រៀន | ២៧នាក់ | ២៨នាក់ | ៥៥នាក់ |
| **សរុប** | ៤១នាក់ | ២៨នាក់ | ៦៩នាក់ |

**តារាងទី២ ៖ កម្រិតវប្បធម៌ ថ្នាក់ដឹកនាំមន្ទីរ ស្រុក នាយក និងគ្រូបង្រៀន**

| កម្រិតវប្បធម៌ | មន្ទីរ | | ស្រុក | | នាយក | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | |
| អនុបណ្ឌិត | ០១ន | ០០ន | | | ០១ន | ០០ន | ០១ន | ០០ន | ០៣នាក់ |
| បរិញ្ញាបត្រ | | | ០៣ន | ០០ន | ០៣ន | ០០ន | ១០ន | ០៥ន | ២១នាក់ |
| ជាប់បាក់ឌុប | | | | | ០៤ន | ០០ន | ១០ន | ២៤ន | ៣៨នាក់ |
| ទាបជាងបាក់ឌុប | | | | | ០២ន | ០០ន | ២ន | ០៣ន | ០៧នាក់ |

តាមតារាងទី២ អ្នកដែលបានចូលរួមឆ្លើយសំណួរសម្ភាសន៍រួមមាន៖ ថ្នាក់ដឹកនាំមន្ទីរអប់រំមាន ០១ នាក់ មានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិត។ ថ្នាក់ដឹកនាំស្រុក ០៣ នាក់ មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ។ នាយកសាលាដែលមានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិតមានចំនួន ០១ នាក់ នាយកសាលាដែលមានបរិញ្ញាប័ត្រមាន ០៣ នាក់ នាយកដែលមានសញ្ញាបត្រជាប់បាក់ឌុបមាន ០៤ និងនាយកសាលា ២ នាក់ទៀតមានកម្រិតវប្បធម៌ក្រោមបាក់ឌុប។ ចំណែកឯគ្រូបង្រៀនវិញចូលរួម សុរបមានចំនួន ៥៥ នាក់ ស្រី ២៨ នាក់ ។ លោកគ្រូអ្នកគ្រូដែលមានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិតមានចំនួន ០១ នាក់ ថ្នាក់បរិញ្ញាបត្រមានចំនួន ១៥ នាក់ ស្រី ០៥ នាក់ ថ្នាក់ជាប់បាក់ឌុបមាន ៣៤ នាក់ និងលោកគ្រូអ្នកគ្រូដែលមានកម្រិតសិក្សាទាបជាងបាក់ឌុប គឺមានចំនួន ០៥ នាក់ ស្រី ០៣ នាក់។ យើងសង្កេតឃើញថា ចំនួនអ្នកចូលរួមដែលមានកម្រិតសញ្ញាបត្របរិញ្ញាបត្រមានចំនួនច្រើនជាងអ្នកដែលមានកម្រិតវប្បធម៌ទាបជាងបរិញ្ញាប័ត្រ ។

**តារាងទី៣៖ បង្ហាញពីបទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់មន្ទីរ**

| បទពិសោធ | ចំនួនអ្នកចូលរួម | ភាគរយ |
|---|---|---|
| 5-10 | 1 នាក់ | 100% |

**តារាងទី៤៖ បង្ហាញពីបទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់ស្រុក**

| បទពិសោធន៍ | ចំនួនអ្នកចូលរួម | ភាគរយ |
|---|---|---|
| 15-25 | 2 | 66.7% |
| 26-45 | 1 | 33.3% |
| សរុប | 3 នាក់ | 100% |

**តារាងទី៥៖ បង្ហាញពីបទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់នាយក**

| បទពិសោធន៍ | ចំនួនអ្នកចូលរួម | ភាគរយ |
|---|---|---|
| 15-25 | 2 | 66.7% |
| 26-45 | 1 | 33.3% |
| សរុប | 3 នាក់ | 100% |

**តារាងទី៦៖ បង្ហាញពីបទពិសោធអ្នកចូលរួមផ្តល់សម្ភាសន៍ក្រុមគ្រូបង្រៀន**

| បទពិសោធន៍ | ចំនួនអ្នកចូលរួម | ភាគរយ |
|---|---|---|
| 1-10 | 20 | 36.4% |
| 11-20 | 16 | 29.1% |
| 21-30 | 7 | 12.7៥% |
| 31-40 | 11 | 20% |
| ៤០ឡើង | 1 | 1.8% |
| សរុប | 55 នាក់ | 100% |

តារាងទី ៣ បង្ហាញពីបទពិសោធការងារគ្រប់គ្រងរបស់ថ្នាក់ដឹកនាំមន្ទីរ គឺ រយៈពេលចន្លោះ ៥-១០ ឆ្នាំមានចំនួន ០១ ស្មើនឹង ១០០%។

តារាងទី ៤ បង្ហាញពីបទពិសោធការងារគ្រប់គ្រងរបស់ថ្នាក់ដឹកនាំស្រុក គឺចន្លោះ ១៥-២៥ ឆ្នាំមានចំនួន ០២ នាក់ ស្មើនឹង ៦៦.៧% និងចន្លោះ ២៦-៤៥ មានចំនួន ០១ នាក់ ស្មើនឹងចំនួន៣៣.៣% ។

តារាងទី៥ បង្ហាញពីបទពិសោធការងារគ្រប់គ្រងរបស់ថ្នាក់ដឹកនាំសាលារៀន គឺ រយៈពេលចន្លោះពី ១-៥ មានចំនួន ០៣ នាក់ ស្មើនឹង ៣០%។ ចន្លោះ ៦-១០ ឆ្នាំមានចំនួន ០៦ នាក់ស្មើនឹង ៦០% និងចន្លោះ ២១-៦០ ឆ្នាំមាន ០១ នាក់ ស្មើនឹង ១០%។

តារាងទី៦ បង្ហាញពីបទពិសោធការងារគ្រប់គ្រងការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូគឺ រយៈពេលចន្លោះពី ១-១០ ឆ្នាំមានចំនួន ២០ នាក់ ស្មើនឹង ៣៦.៤%។ ចន្លោះ ១១-២០ ឆ្នាំមានចំនួន ១៦ នាក់ ស្មើនឹង ២០.១%។ ចន្លោះ ២១-៣០ ឆ្នាំមានចំនួន

០៧ នាក់ ស្មើនឹង ១២.៧%។ ចន្លោះ ៣១-៤០ ឆ្នាំមានចំនួន ១១ នាក់ ស្មើនឹង ២០% និង លើសពី ៤០ ឆ្នាំទៅមានចំនួន ០១ នាក់ ស្មើនឹង ១.៨%។

ដូច្នេះ យើងសង្កេតឃើញថាលោកគ្រូអ្នកគ្រូ នាយក ប្រធានការិយាល័យស្រុក និងថ្នាក់ដឹកនាំមន្ទីរគឺសុទ្ធតែមានបទពិសោធច្រើនឆ្នាំក្នុងការគ្រប់គ្រង និងបង្រៀន ។

**តារាងទី៧៖ បង្ហាញពីចំនួនថ្នាក់គ្រប់គ្រងមន្ទីរបានដឹងពីកម្មវិធីអំណានដំបូង**

| ថ្នាក់មន្ទីរ | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 1 | 100% |

**តារាងទី៨៖ បង្ហាញពីចំនួនថ្នាក់គ្រប់គ្រងស្រុកបានដឹងពីកម្មវិធីអំណានដំបូង**

| ថ្នាក់ស្រុក | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 3 | 100% |

**តារាងទី៩៖ បង្ហាញពីចំនួននាយកដែលបានដឹងពីកម្មវិធីអំណានដំបូង**

| នាយកសាលា | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 9 | 90% |
| មិនធ្លាប់ | 1 | 10% |
| សរុប | 10 | 100% |

**តារាងទី១០៖ បង្ហាញពីចំនួនគ្រូបង្រៀនដែលបានដឹងពីកម្មវិធីអំណានដំបូង**

| គ្រូបង្រៀន | ចំនួន | ភាគរយ |
|---|---|---|
| មិនធ្លាប់ | 17 | 30.9% |
| ធ្លាប់ | 38 | 69.1% |
| សរុប | 55 | 100% |

តាមតារាងទី ៧ រហូតដល់ទី ១០ យើងសង្កេតឃើញថាចំនួនអ្នកធ្លាប់បានដឹងអំពី អំណានដំបូងគឺ ថ្នាក់ដឹកនាំមន្ទីរ ០១ នាក់ស្មើនឹង ១០០% ថ្នាក់ដឹកនាំស្រុក ០៣ នាក់ ស្មើនឹង ១០០% នាយកសាលាចំនួន ០៩ នាក់ស្មើនឹង ៩០% និងមិនធ្លាប់មាន ០១ ស្មើ នឹង ១០% ។ ចំណែកក្រុមគ្រូបង្រៀនវិញ យើងសង្កេតឃើញថា មានគ្រូចំនួន ៣៨ នាក់

ស្មើនឹង ៦៩.១% ធ្លាប់ដឹងពីកម្មវិធីអំណានដំបូង និងគ្រូចំនួន ១៧នាក់ ដែលមិនធ្លាប់បានដឹងពីកម្មវិធីនេះ ។

ដូចនេះយើងអាចសន្និដ្ឋានបានថា ចំនួនអ្នកដែលធ្លាប់បានដឹងពីកម្មវិធីអំណានដំបូងគឺមានបរិមាណច្រើនជាងអ្នកដែលមិនធ្លាប់ដឹង ។

**តារាងទី១១៖ បង្ហាញពីថ្នាក់មន្ទីរធ្លាប់ចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង**

| ថ្នាក់មន្ទីរ | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 1 | 100% |

**តារាងទី១២៖ បង្ហាញពីថ្នាក់ស្រុកធ្លាប់ចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង**

| ថ្នាក់ស្រុក | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 3 | 100% |

**តារាងទី១៣៖ បង្ហាញពីនាយកធ្លាប់បានចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង**

| នាយក | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 3 | 30% |
| មិនធ្លាប់ | 7 | 70% |
| សរុប | 10 | 100% |

**តារាងទី១៤៖ បង្ហាញពីគ្រូបង្រៀនធ្លាប់ចូលរួមសិក្ខាសាលាពីកម្មវិធីអំណានដំបូង**

| គ្រូបង្រៀន | ចំនួន | ភាគរយ |
|---|---|---|
| មិនធ្លាប់ | 27 | 49.1% |
| ធ្លាប់ | 28 | 50.9% |
| សរុប | 55 | 100% |

តាមរយៈតារាងទី ១១ ដល់ទី ១៤ យើងសង្កេតឃើញថាចំនួនថ្នាក់ដឹកនាំ និងគ្រូបង្រៀនដែលធ្លាប់បានចូលរួមសិក្ខាសាលាគឺថ្នាក់មន្ទីរ ១០០% ថ្នាក់ដឹកនាំស្រុក ១០០% នាយកមានចំនួន ០៣ នាក់ធ្លាប់បានចូលរួមសិក្ខាសាលាស្មើនឹង ៣០% និងមិនធ្លាប់ចំនួន ០៧ នាក់ ស្មើនឹង ៧០%។ ចំពោះគ្រូបង្រៀនមានចំនួនអ្នកមិនធ្លាប់ចូលរួមមាន ២៧ នាក់ ស្មើនឹង ៤៩.១% និង ចំនួន ២៨ នាក់ធ្លាប់បានចូលរួមស្មើនឹង ៥០.៩%។

ជារួមយើងសង្កេតឃើញមានចំនួនអ្នកធ្លាប់ចូលរួមសិក្ខាសាលាអំពីអំណាននៅតែមានចំនួនច្រើនជាងអ្នកដែលមិនធ្លាប់ដដែល ។

**តារាងទី១៥៖ បង្ហាញពីគ្រូដែលធ្លាប់បង្រៀនទាក់ទងពីសកម្មវិធីអំណានដំបូង**

| គ្រូបង្រៀន | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាប់ | 35 | 63.6% |
| ធ្លាប់ខ្លះៗ | 18 | 32.7% |
| មិនធ្លាប់ | 2 | 3.6% |
| សរុប | 55 | 100% |

ទោះបីជាការបង្រៀនអំណានដំបូង មិនទាន់បានអនុវត្តនៅទីរួមខេត្តតាកែវក៏ដោយ តាមការស្រាវជ្រាវបង្ហាញក្នុងតារាងទី ១៥ សង្កេតឃើញថា គ្រូបង្រៀនដែលធ្លាប់បង្រៀនទាក់ទងទៅនឹងសកម្មភាពទាំង ០៧នៃអំណានដំបូងមានចំនួន ៣៥ នាក់ស្មើនឹង ៦៣.៦% និងធ្លាប់ខ្លះៗមានចំនួន ១៨ នាក់ស្មើនឹង ៣២.៧% ចំណែកគ្រូដែលមិនធ្លាប់មាន ០២ នាក់ស្មើនឹង ៣.៦% ប៉ុណ្ណោះ ។

ចំនួននេះអាចបញ្ជាក់បានថា លោកគ្រូអ្នកគ្រូពិតជាមានសមត្ថភាពក្នុងការបង្រៀនកម្មវិធីអំណានដំបូងនេះបានយ៉ាងប្រាកដ។

## ៤.១.២. លទ្ធភាពនៃការអនុវត្តការអនុវត្តអំណានដំបូងនៅបឋមសិក្សា

### ៤.១.២.១. ការបង្រៀនស្គាល់ស្ងួរអក្សរថ្មី

**តារាងទី១៦៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនស្គាល់ស្ងួរ**

| ការបង្រៀនស្គាល់ស្ងួរថ្មី | ចំនួនគ្រូបង្រៀន | ភាគរយ |
|---|---|---|
| បង្រៀនបាន | 30 | 54.5% |
| បង្រៀនបានខ្លះ | 17 | 30.9% |
| បង្រៀនបានតិច | 8 | 14.5% |
| សរុប | 55 | 100% |

តាមតារាងទី ១៦ យើងសង្កេតឃើញថា គ្រូភាគច្រើនមានលទ្ធភាពក្នុងការបង្រៀនសិស្សឲ្យស្គាល់ស្ងួរអក្សរថ្មី ដោយសារពួកគាត់ធ្លាប់បានដឹង បានចូលរួមសិក្ខាសាលាទាក់ទងការបង្រៀនអំណាន និងមានបទពិសោធផ្ទាល់ក្នុងការបង្រៀនច្រើនឆ្នាំ។

ចំណែកគ្រូមួយចំនួនពួកគាត់មានលទ្ធភាពក្នុងការបង្រៀនខ្លះៗដែរ ដោយសារពួកគាត់ធ្លាប់បានដឹង និងធ្លាប់មានបទពិសោធពីមុនមកក្នុងការបង្រៀន។ ដោយឡែកក៏មានគ្រូមួយចំនួនស្ទើរតែមិនអាចបង្រៀនបាន ពីព្រោះពួកគាត់មិនធ្លាប់ដឹង មិនធ្លាប់ចូលរួមសិក្ខាសាលា និងមិនមានបទពិសោធបង្រៀនពីមុនមកទេ ។

### ៤.១.២.២. ការបង្រៀនស្គាល់តួអក្សរថ្មី

**តារាងទី១៧៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនស្គាល់តួអក្សរ**

| ការបង្រៀនស្គាល់តួអក្សរថ្មី | ចំនួនគ្រូបង្រៀន | ភាគរយ |
|---|---|---|
| បង្រៀនបាន | 41 | 74.5% |
| បង្រៀនបានខ្លះ | 12 | 21.8% |
| បង្រៀនបានតិច | 1 | 1.8% |
| បង្រៀនមិនបាន | 1 | 1.8 |
| សរុប | 55 | 100% |

តាមតារាងទី ១៧ បង្ហាញថា គ្រូភាគច្រើនមានលទ្ធភាពបង្រៀនសិស្សឲ្យស្គាល់តួអក្សរ ដោយសារពួកគាត់ធ្លាប់ដឹង និងបានចូលរួមសិក្ខាសាលាពីខាងអំណាន មានបទពិសោធន៍ក្នុងការបង្រៀនផ្ទាល់យូរឆ្នាំ ។ ចំណែកគ្រូខ្លះទៀតពួកគាត់អាចបង្រៀនបានខ្លះដែរ ព្រោះធ្លាប់ដឹង និងបង្រៀនពីមុនមក ។ ចំពោះគ្រូខ្លះទៀតគឺមិនអាចបង្រៀនបានទេ ដោយហេតុតែពួកគាត់មិនបានដឹង និងមិនមានបទពិសោធន៍បង្រៀនទេ ។

### ៤.១.២.៣. ការបង្រៀនអានព្យាង្គ និងពាក្យ

**តារាងទី១៨៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនអានព្យាង្គ**

| **ការបង្រៀនព្យាង្គ** | **ចំនួនគ្រូបង្រៀន** | **ភាគរយ** |
|---|---|---|
| បង្រៀនបាន | 30 | 54.5% |
| បង្រៀនបានខ្លះ | 16 | 29.1% |
| បង្រៀនបានតិច | 6 | 10.9% |
| បង្រៀនមិនបាន | 3 | 5.5% |
| **សរុប** | 55 | 100% |

នៅក្នុងតារាងទី ១៨ ខាងលើគ្រូជាងពាក់កណ្ដាលគឺមានលទ្ធភាពក្នុងការបង្រៀនសិស្សឲ្យចេះអានព្យាង្គ។ ចំណែកគ្រូមួយចំនួនទៀត គឺបង្រៀនបានខ្លះ និង គ្រូបង្រៀនមួយចំនួនតូច ស្ទើរតែគ្មានលទ្ធភាពបង្រៀន និងគ្មានតែម្ដង ។

ដូច្នេះគ្រូភាគច្រើនមានលទ្ធភាពក្នុងការបង្រៀន ពីព្រោះពួកគាត់មានបទពិសោធន៍បង្រៀន ចូលរួមសិក្ខាសាលា និងវគ្គបំប៉នអំណាន ។

### ៤.១.២.៤.ការបង្រៀនពាក្យខាក្យសព្ទ

**តារាងទី១៩៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនវាក្យសព្ទ**

| ការបង្រៀនវាក្យសព្ទ | ចំនួនគ្រូបង្រៀន | ភាគរយ |
|---|---|---|
| បង្រៀនបាន | 31 | 56.4% |
| បង្រៀនបានខ្លះ | 13 | 23.6% |
| បង្រៀនបានតិច | 9 | 16.4% |
| បង្រៀនមិនបាន | 2 | 3.6% |
| សរុប | 55 | 100% |

ផ្អែកលើតារាងទី ១៩ មានគ្រូបង្រៀនជាច្រើនមានលទ្ធភាពបង្រៀនសិស្សឲ្យចេះវាក្យសព្ទ ពីព្រោះពួកគាត់មានបទពិសោធន៍បង្រៀនច្រើនឆ្នាំ ចូលរួមសិក្ខាសាលា និងវគ្គបំប៉នអំណាន។ រីឯគ្រូមួយចំនួនទៀត ក៏មានលទ្ធភាពខ្លះដែរក្នុងការបង្រៀន មូលហេតុពួកគាត់ធ្លាប់ដឹង និងធ្លាប់មានបទពិសោធន៍ពីមុនៗមក ។ រីឯគ្រូមួយចំនួនតូចទៀត មានលទ្ធភាពតិចតួច និងគ្មានតែម្ដង ពីព្រោះមិនធ្លាប់បានដឹង និងបង្រៀនពីមុនមកទេ ។

សរុបមក គ្រូភាគច្រើនមានចំណេះដឹង និងបទពិសោធន៍ច្រើនក្នុងការបង្រៀនវាក្យសព្ទ ឬបង្រៀនសិស្សឲ្យយល់ន័យរបស់ពាក្យ ។

### ៤.១.២.៥. ការបង្រៀនអានល្បះ

**តារាងទី២០៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនអានល្បះ**

| ការបង្រៀនអានល្បះ | ចំនួនគ្រូបង្រៀន | ភាគរយ |
|---|---|---|
| បង្រៀនបាន | 22 | 40% |
| បង្រៀនបានខ្លះ | 24 | 43.6% |
| បង្រៀនបានតិច | 5 | 9% |

| | | |
|---|---|---|
| បង្រៀនមិនបាន | 4 | 7.3% |
| សរុប | 55 | 100% |

ផ្អែកលើតារាងទី ២០ មានគ្រូចំនួនច្រើនជាងពាក់កណ្ដាលមានលទ្ធភាពក្នុងការបង្រៀនសិស្សអំពីការអានល្បះ មូលហេតុពួកគាត់ភាគច្រើនគឺពុំសូវមានបទពិសោធន៍ក្នុងការបង្រៀនអានល្បះ និងពុំធ្លាប់ដឹងច្រើន។ រីឯគ្រូតិចជាងពាក់កណ្ដាលគឺមានលទ្ធភាពបង្រៀន ដោយសារគាត់មានបទពិសោធបង្រៀនផ្ទាល់ និងបង្រៀនច្រើនឆ្នាំ។ ប៉ុន្តែយើងក៏សង្កេតឃើញមានក្រុមគ្រូបង្រៀនមួយភាគតូច មានលទ្ធភាពអាចបង្រៀនបានតិចតួច និងខ្លះទៀតគឺគ្មានសោះ នេះដោយសារពួកគាត់មិនធ្លាប់បានដឹង និងគ្មានបទពិសោធន៍បង្រៀនពីមុនទេ ។ ដូចនេះ គឺនៅមានគ្រូបង្រៀនភាគច្រើនអាចបង្រៀនបានខ្លះៗតែប៉ុណ្ណោះ និងគ្រូតិចជាងពាក់កណ្ដាលមានលទ្ធភាពបង្រៀនបាន ។

### ៤.១.២.៦. ការបង្រៀនអានអត្ថបទខ្លី

**តារាងទី២១៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនអានអត្ថបទខ្លី**

| ការបង្រៀនអានអត្ថបទ | ចំនួនគ្រូបង្រៀន | ភាគរយ |
|---|---|---|
| បង្រៀនបាន | 12 | 21.8% |
| បង្រៀនបានខ្លះ | 23 | 41.8% |
| បង្រៀនបានតិច | 13 | 23.6% |
| បង្រៀនមិនបាន | 7 | 12.7% |
| សរុប | 55 | 100% |

តាមតារាងទី២១ បានបង្ហាញថា មានគ្រូបង្រៀនភាគតិចអាចបង្រៀនពីការអានអត្ថបទខ្លី ពីព្រោះពួកគាត់ភាគច្រើនមិនមានបទពិសោធក្នុងការបង្រៀន មិនធ្លាប់ទទួលបានចំណេះដឹងខាងបង្រៀនអត្ថបទទេ។ ចំណែកគ្រូបង្រៀនស្ទើរពាក់កណ្ដាលមានលទ្ធភាពខ្លះៗចំពោះការបង្រៀន និងគ្រូស្ទើពាក់កណ្ដាលបង្រៀនបានតិចតួចបំផុត និងខ្លះមិនអាចបង្រៀនបានទេ។ ដូច្នេះបញ្ជាក់ថាគ្រូបង្រៀនភាគច្រើនមិនមានលទ្ធភាពបង្រៀនសិស្សឲ្យចេះអានអត្ថបទទេ។

### ៤.១.២.៧. ការបង្រៀនសរសេរ

**តារាងទី២២៖ បង្ហាញពីគ្រូបង្រៀនទាក់ទងការបង្រៀនសរសេរ**

| ការបង្រៀនសរសេរ | ចំនួនគ្រូបង្រៀន | ភាគរយ |
|---|---|---|
| បង្រៀនបាន | 27 | 49.1% |
| បង្រៀនបានខ្លះ | 15 | 27.3% |
| បង្រៀនបានតិច | 6 | 10.9% |
| បង្រៀនមិនបាន | 7 | 12.7% |
| សរុប | 55 | 100% |

តាមតារាងទី ២២ ដែលបានបង្ហាញខាងលើសង្កេតឃើញថា មានចំនួនគ្រូចំនួនភាគច្រើនដែលមានលទ្ធភាពក្នុងការបង្រៀនសិស្សឲ្យចេះសរសេរ ពីព្រោះដោយសារគាត់ធ្លាប់ដឹង ធ្លាប់ចូលរួមសិក្ខាសាលា និងមានបទពិសោធន៍បង្រៀនទាក់ទងនឹងការសរសេរ និងគ្រូមួយចំនួនទៀតមានសមត្ថភាពបង្រៀនបានតិចតួច រីឯខ្លះទៀតមិនអាចបង្រៀនបានដោយសារពួកគាត់មិនធ្លាប់បានដឹង មិនធ្លាប់ចូលរួមកម្មវិធីសិក្ខាសាលា និងមិនមានបទពិសោធន៍បង្រៀន។ ដូចនេះចំនួនគ្រូដែលអាចមានសមត្ថភាពបង្រៀនទាក់ទងការសរសេរបានគឺមានចំនួនប្រហាក់ប្រហែលទៅនឹងចំនួនគ្រូដែលមិនមានលទ្ធភាពបង្រៀន ។

សរុបសេចក្តីមក តាមលទ្ធលស្រាវជ្រាវខាងលើ លើការបង្រៀនសកម្មភាពបង្រៀនទាំង ៧ ទាក់ទងនឹងកញ្ចប់សម្ភារៈអំណានដំបូង យើងអាចនិយាយបានថាចំនួនលោកគ្រូអ្នកគ្រូភាគច្រើនអាចមានលទ្ធភាពបង្រៀនអំណានដំបូង ដោយសារតែពួកគាត់ធ្លាប់បានដឹង និងមានចូលរួមវគ្គសិក្ខាសាលាបំប៉នផ្សេងៗ និងមានបទពិសោធន៍បង្រៀនយូរឆ្នាំ ដូចបានបង្ហាញជូននៅក្នុងតារាងទី៥ ទី១០ ទី១៤ និងទី១៥ ។ ចំណែកឯក្រុមគ្រូបង្រៀនមួយចំនួនទៀតក៏មានលទ្ធភាពបង្រៀនច្រើនគួរសមដែរ ពីព្រោះពួកគាត់ធ្លាប់ដឹង ធ្លាប់អានពីការបង្រៀនអំណានតាមឯកសារជំនួយគ្រូ ទស្សនាវដ្តីគ្រូបង្រៀន និងធ្លាប់មានបទពិសោធបង្រៀនពីឆ្នាំមុនៗ ។ ដោយឡែកក្នុងនោះក៏មានគ្រូបង្រៀនមួយចំនួនតូច គឺមិនអាចបង្រៀនបានទេ មូលហេតុគឺពួកគាត់ មិនធ្លាប់ដឹង មិនធ្លាប់ចូលរួមសិក្ខាសាលា និងមិនធ្លាប់បង្រៀនកម្រិតថ្នាក់តូច ឬបង្រៀនខុសកម្រិតថ្នាក់ជំនាញរបស់គាត់ដូចបានបង្ហាញជូននៅក្នុងសំណួរស្រាវជ្រាវទី ២ ស្រាប់។

# ជំពូកទី ៥

# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវយល់ឃើញថា ការអនុវត្តអំណានដំបូងនៅតាមសាលាបឋមសិក្សា ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយគ្រូបង្រៀននូវរាល់វិធីសាស្ត្របង្រៀនអំណានដល់សិស្សដើម្បីជួយអភិវឌ្ឍសមត្ថភាពអានរបស់សិស្សក៏ដូចជាការជួយអភិវឌ្ឍគុណភាពអប់រំ។ ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមមន្ទីរអប់រំ ការិយាល័យអប់រំស្រុក ០៣ និងសាលារៀនចំនួន ១០នៅបឋមសិក្សា នៅក្នុងខេត្តតាកែវ ។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើលទ្ធភាពនៃការអនុវត្តអំណានដំបូងនៅកម្រិតបឋមសិក្សារួមមាន ទ្រព្យធនដែលមានស្រាប់នៅតាមអង្គភាពដូចជា មន្ទីរ ស្រុក សាលារៀននិងសមត្ថភាពថ្នាក់ដឹកនាំមន្ទីរ ក្រុង/ស្រុក នាយកសាលា និងគ្រូបង្រៀនគឺ ចំណេះដឹង និងបទពិសោធ ធៀបទៅនឹងវិធីសាស្ត្រដែលមាននៅក្នុងសៀវភៅកញ្ចប់សម្ភារៈអំណានដំបូង។

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យបឋមនៅតាមមន្ទីរ ស្រុក/ក្រុង និងសាលាគោលដៅ ដោយផ្តល់ជូនថ្នាក់ដឹកនាំមន្ទីរ ០១ នាក់ ថ្នាក់ប្រធានការិយាល័យស្រុក ០៣ នាក់ នាយកសាលា ១០ នាក់ គ្រូបង្រៀន ៥៥ នាក់ ដើម្បីបំពេញនិងធ្វើការសម្ភាសន៍ ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី SPSS និង Excel ដោយវិភាគតាម Frequencies And Descriptive ដោយបង្ហាញជាតារាងស្ថិតិ។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា លទ្ធភាពនៃការអនុវត្តអំណានដំបូងនៅបឋមសិក្សា មានចំណុចល្អច្រើនដូចជា៖

១). មន្ទីរអប់រំខេត្តមានលទ្ធភាពអនុវត្ត ផ្អែកលើសមត្ថភាពរបស់គ្រូឧទ្ទេសក្នុងការប្រជុំផ្លាស់ប្តូរបទពិសោធន៍ដល់គ្រូបង្គោលតាមកម្រិតថ្នាក់

២). ការិយាល័យក្រុង/ស្រុកមានលទ្ធភាពអនុវត្តដោយសារ គ្រូបង្រៀនធ្លាប់បានចូលរួមការបណ្តុះបណ្តាលថ្នាក់ទី ១ រយៈពេល ៨ សប្តាហ៍ដំបូងក្នុងការអប់រំកុមារអាយុ ៦ ឆ្នាំមិនឆ្លងកាត់មត្តេយ្យសិក្សា និងតាមរយៈអង្គការដៃគូពាក់ព័ន្ធក្នុងការជួយឧបត្ថម្ភ

៣). នាយកសាលាក៏មានលទ្ធភាពក្នុងការអនុវត្តដែរ ពីព្រោះមានការផ្លាស់ប្តូរបទពិសោធន៍បង្រៀនតាមកម្រិតថ្នាក់ពេលប្រជុំបច្ចេកទេសប្រចាំខែ ថវិកាគ្រោងទុកផលិតនិងចែកជូន សម្ភារៈតាមលទ្ធភាពដែលអាចធ្វើទៅបានរបស់សាលារៀន ៤) ចំណែកគ្រូបង្រៀនភាគច្រើនជាងពាក់កណ្តាល គឺមានលទ្ធភាពបង្រៀនអំណានដំបូងតាមរយៈការសម្ភាស និងវិភាគលើចម្លើយរបស់ពួកគាត់ធៀនទៅនឹងកញ្ចប់សម្ភារៈអំណានដំបូង ដោយពួកគាត់ ធ្លាប់ដឹងធ្លាប់ចូលរួមកម្មវិធីបណ្តុះបណ្តាលវគ្គខ្លីៗ និងមានបទពិសោធបង្រៀនផ្ទាល់នៅកម្រិតថ្នាក់តូចៗច្រើនឆ្នាំ។ ចំណែកនាយកសាលាមួយចំនួនតូចមានប្រសាសន៍ថាគាត់ពុំមានលទ្ធភាពអនុវត្តកម្មវិធីនេះទេដោយផ្អែកលើហេតុផលដូចជា៖ មិនទាន់យល់ច្បាស់ពីកម្មវិធីនេះ មិនមានសម្ភារៈឯកសារ មិនមានគ្រូឧទ្ទេស និងខ្វះថវិកាចំណាយលើកម្មវិធីអំណានដំបូង។ ចំណែកគ្រូបង្រៀនមួយចំនួន គឺមានលទ្ធភាពបង្រៀនបានខ្លះដែរ ដោយសារពួកគាត់ធ្លាប់ដឹង និងធ្លាប់មានបទពិសោធន៍បង្រៀនកម្រិតថ្នាក់តូចពីមុនៗមក។ រីឯមួយចំនួនតូចទៀត គឺមិនអាចបង្រៀនបានទេ ពីព្រោះពួកគាត់ មិនធ្លាប់បានដឹង បានចូលរួមកម្មវិធីវគ្គខ្លីៗខាងអំណាន និងមិនមានបទពិសោធន៍បង្រៀនពីមុនមកទេ។

## ៥.២. សំណូមពរ

ខាងក្រោមនេះជាសំណូមពររបស់ ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្តតាកែវ ប្រធានការិយាល័យអប់រំស្រុក លោកនាយកសាលា និងលោកគ្រូអ្នកគ្រូ ជូនចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ៖

- ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត ៖ ១) ត្រូវមានកញ្ចប់ថវិកាតាមដានកម្មវិធីអំណានដំបូង ២) ផ្តល់កញ្ចប់សម្ភារៈអំណានដំបូង និងបំប៉នគ្រូបង្គោលឲ្យចំ

គោលដៅ ៣) ស្នើសុំការប្រជុំបច្ចេកទេសឲ្យបង្កើនថវិកាពី ៥០០០ រៀល ទៅ ១០០០០ រៀល បើអាចធ្វើបាន។

- ថ្នាក់ដឹកនាំប្រធានការិយាល័យអប់រំស្រុក ៖ ១) បើវគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងគ្រូបង្រៀនកម្រិតថ្នាក់អំណានដំបូង ២) ស្នើសុំកញ្ចប់សម្ភារៈអំណានដំបូង និងឯកសារគាំទ្រផ្សេងៗ ៣) ស្នើសុំកញ្ចប់ថវិកាបន្ថែមលើពីកម្មវិធីអំណានដំបូង និងត្រួតពិនិត្យតាមដាន។
- នាយកសាលា៖ ១) ស្នើសុំឲ្យក្រសួងមានកម្មវិធីច្បាស់លាស់ និងត្រូវដាក់បញ្ចូលតាមសាលា ២) បង្កើតកម្មវិធីសិក្ខាសាលាថ្នាក់អំណានដំបូង ៣) មានឯកសារគ្រប់គ្រាន់ទាក់ទងអំណានដំបូងសម្រាប់ចែកជូនដល់គ្រូបង្រៀន ៤) ផ្តល់កញ្ចប់ថវិកាដំណើរការផ្នែកអំណានដំបូងសម្រាប់សាលារៀនបន្ថែម។
- លោកគ្រូអ្នកគ្រូបង្រៀន ៖ ១) សូមឲ្យក្រសួងបង្កើតវគ្គសិក្ខាសាលាបណ្តុះបណ្តាលដល់គ្រូបង្រៀនឲ្យបានឆាប់ និងញឹកញាប់ ២) ផ្តល់ជូនគ្រូបង្រៀននូវកញ្ចប់សម្ភារៈអំណានដំបូង ៣) ស្នើសុំឲ្យថ្នាក់ក្រសួងបង្កើតវគ្គសិក្ខាសាលាសម្រាប់គ្រូឲ្យចំគោលដៅ

# ឯកសារយោង


១. សៀវភៅសិក្សាគោលថ្នាក់ទី១ ទី២ និងទី៣ របស់ក្រសួងអប់រំយុវជន និងកីឡា

២.សៀវភៅអំណានស្តង់ដាថ្នាក់ទី១ ទី២ និងទី៣ (សៀវភៅណែនាំគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្ស)

៣. សៀវភៅជំនួយភាសាខ្មែរថ្នាក់ទី១ ភាគ១- ភាគ២ សម្រាប់សិស្សអាន និងសរសេរ

៤. សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១ ភាគ១-ភាគ២ ស្តីអំពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោល ភាសាខ្មែរ អាន- និងសរសេរ(កញ្ចប់សម្ភារៈអំណានដំបូង)

៥. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា

៦. និក្ខេបបទគំរូរបស់លោក ស៊ន សុខដុម ជំនាន់ទី៣

៧. អត្ថបទទស្សនៈព្រឹត្តិការណ៍ខ្មែរ សំឡេងពិភពលោក

៨. លទ្ធផល តេស្ត អឺហ្ក្រា ឆ្នាំ២០១៧-២០១៨

៩. របាយការណ៍ដែលបានចុះផ្សាយរបស់កាសែតភ្នំពេញប៉ុស្តិ៍

១០. USAID (ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ)

១១. របាយការណ៍របស់ World Bank ឆ្នាំ ២០១៤

១២. https://archive.monoroom.info/news/post/67#1PIEG5vMUufoiDU4.99

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ [illegible] អយក.[illegible]

ថ្ងៃ[illegible] ខែចេត្រ ឆ្នាំ[illegible] ស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

